# គោលដៅរបស់យើង – សិរីរុងរឿងរបស់ព្រះជាម្ចាស់
# OUR TARGET – GOD'S GLORY

## សេចក្តីសង្ខេប

គ្រីស្ទបរិស័ទរាប់មិនអស់នៅជុំវិញពិភពលោកជឿដោយមានការរំពឹងទុកថា ដំណឹងល្អគួរតែនាំឱ្យមានការបំផ្លាស់បំប្រែបុគ្គល និងសហគមន៍។ ទោះបីយ៉ាងណាក៏ដោយ មនុស្សភាគច្រើនមិនបានមើលឃើញការបំផ្លាស់បំប្រែដែលពួកគេរំពឹងចង់បានទេ។ ហេតុអ្វី? នោះគឺជាការយល់ដឹងមិនពេញលេញអំពីគោលបំណងចុងក្រោយរបស់មហាបេសកកម្ម និងទំនាក់ទំនងរបស់មហាបេសកកម្មជាមួយគោលបំណងរបស់ព្រះជាម្ចាស់ គឺសិរីល្អរបស់ព្រះអង្គ។

## <u>គំនិតចម្បង: ផ្នែកទី ១</u>

១. ការយកព្រះហឫទ័យទុកដាក់ចម្បងរបស់ព្រះជាម្ចាស់គឺជាសិរីល្អរបស់ព្រះអង្គ។

២. ព្រះជាម្ចាស់ត្រូវបានថ្វាយសិរីល្អយ៉ាងប្រសើរបំផុត នៅពេលដែលស្នាព្រះហស្តដ៏វិសេសរបស់ព្រះអង្គ គឺមនុស្សរស់នៅតាមរបៀបដែលព្រះអង្គបានតាក់តែងពួកគេឱ្យរស់នៅ គឺរស់នៅស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះអង្គ។

៣. នៅពេលដែលយើងរស់នៅដោយស្តាប់បង្គាប់ យើងចូលរួមនៅក្នុងការស្រឡាញ់ដល់គ្នាទៅវិញទៅមកយ៉ាងអស្ចារ្យដែលមាននៅក្នុងព្រះត្រៃឯក។

៤. គោលបំណងរបស់មហាបេសកកម្មគឺបង្រៀនការស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះគ្រីស្ទ។ ការប្រកាសដំណឹងល្អ ការដាំក្រុមជំនុំ និងការបង្រៀនមនុស្សពីសេចក្តីពិតនៅក្នុងព្រះគម្ពីរគឺជាជំហានសំខាន់ៗ ប៉ុន្តែគ្រាន់តែជាជំហានដើម្បីសម្រេចព្រះបន្ទូលណែនាំចុងក្រោយរបស់ព្រះយេស៊ូវដល់ពួកសិស្សរបស់ព្រះអង្គ។

៥. ការបំផ្លាស់បំប្រែមិនមែនជាអ្វីមួយដែលមនុស្ស ឬស្ថាប័នរបស់ពួកគេអាចសម្រេចបានទេ។ ការបំផ្លាស់បំប្រែគឺជាកិច្ចការយ៉ាងអស្ចារ្យរបស់ព្រះជាម្ចាស់ ជាការឆ្លើយតបទៅនឹងលក្ខខណ្ឌដែលព្រះអង្គបានបង្កើតសម្រាប់ការប្រោសយើងឱ្យជា មានការបន្ទាបខ្លួន ការប្រែចិត្ត និងការរស់នៅដោយស្តាប់បង្គាប់។

## <u>គំនិតចម្បង: ផ្នែកទី ២</u>

១. គោលការណ៍អនុវត្តប្រាំពីរ

**<u>លទ្ធផលៈ</u>**

១. ឥឡូវនេះ

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ ។

ខ. រៀបចំផែនការ និងអនុវត្តជំហានថ្មីមួយនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ជាការឆ្លើយតបចំពោះមេរៀននេះតាមរយៈសកម្មភាពបម្រើជាក់ស្តែងប្រកបដោយសេចក្តីស្រឡាញ់ ។

២. ទៅមុខទៀត

ក. រស់នៅតាមសេចក្តីប្រាប់ដោយប្រយោលនៃកិច្ចការចុងក្រោយរបស់មហាបេសកកម្មនៅក្នុងព័ន្ធកិច្ចរបស់សិក្ខាកាម ។

ខ. វាយតម្លៃព័ន្ធកិច្ចរបស់សិក្ខាកាមតាមកម្រិតដែលព័ន្ធកិច្ចនោះរួមចំណែកនៅក្នុងការស្តាប់បង្គាប់នៃសិស្សរបស់ពួកគេតាមបញ្ញត្តិរបស់ព្រះយេស៊ូវ ។

# គោលដៅរបស់យើង ~ សិរីរុងរឿងរបស់ព្រះជាម្ចាស់
## គ្រោងមេរៀន

១. រឿងពីប្រទេសប្រេស៊ីល

២. សិរីរុងរឿងរបស់ព្រះជាម្ចាស់

ក. តើទីបញ្ចប់ជាចម្បងរបស់មនុស្សគឺជាអ្វី?

ខ. ទីបញ្ចប់ជាចម្បងរបស់មនុស្សគឺជា:

១. ថ្វាយសិរីល្អដល់ព្រះជាម្ចាស់

២. នៅជាមួយព្រះអង្គអស់កល្បជានិច្ច

គ. ទំនាក់ទំនងនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ជាមួយនឹងមហាបេសកកម្ម

៣. ការបង្កើតចក្រវាឡ

ក. ទំនុកដំកើង ១១៩:១-៤

ខ. ការបង្កើត

១. ទំហំគ្មានដែនកំណត់ ថ្ងៃលិច ម៉ូលេគុលស្មុគស្មាញ

៤. ពាក្យពណ៌នាអត្តចរិតរបស់ព្រះជាម្ចាស់

ក. ធំឧត្តម ស័ក្តិសម គួរឱ្យគោរព មានសោភ័ណភាព មានតេជានុភាព គ្មានឧបាយកល មានសេចក្តីស្រឡាញ់ បរិសុទ្ធ មេត្តាករុណា យុត្តិធម៌ អត់ធ្មត់ មានព្រះចេស្តា ការពារ មានព្រះបារមី ស្ម័គ្រចិត្តលះបង់ខ្លួនឯង មានសិរីល្អ។

៥. សិរីរុងរឿងរបស់ព្រះជាម្ចាស់

ក. គួរឱ្យស្ញប់ស្ញែង និងគួរឱ្យកោតខ្លាច

ខ. មានព្រះហឫទ័យស្រឡាញ់ និងអោបក្រសោប

៦. សិរីរុងរឿងរបស់ព្រះជាម្ចាស់ - ការយកព្រះទ័យទុកដាក់ជាចម្បងរបស់ព្រះអង្គ

ក. ព្រះជាម្ចាស់ចង់ឱ្យប្រជារាស្ត្ររបស់ព្រះអង្គឆ្លុះបញ្ចាំងសិរីរុងរឿងរបស់ព្រះអង្គ

១. សង្ឃដល់ប្រជាជាតិនានាដែលកំពុងសង្កេតមើល ចោទិយកថា ៤:៥-៨

២. ពន្លឺដើម្បីឱ្យអ្នកសង្កេតមើលសរសើរតម្កើងព្រះវរបិតានៃយើង ម៉ាថាយ ៥:១៦

៣. ត្រូវបានជ្រើសរើសសម្រាប់សិរីល្អរបស់ព្រះអង្គ (បីដង) អេភេសូរ ១:១-១៤

៤. ធ្វើគ្រប់កិច្ចការសម្រាប់ជាសិរីល្អរបស់ព្រះជាម្ចាស់ ១កូរិនថូស ១០:៣១

៥. រស់នៅដើម្បីឱ្យអ្នកសង្កេតមើលថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ១ ពេត្រុស ២:១២

៧. ព្រះជាម្ចាស់ - សិរីរុងរឿងរបស់យើង យើងជាសិរីរុងរឿងរបស់ព្រះអង្គ

ក. ព្រះជាម្ចាស់ជាសិរីល្អរបស់យើង ជាពន្លឺដ៏នៅអស់កល្បជានិច្ច អេសាយ ៦០:១៩

ខ. យើងគឺជាសិរីរុងរឿងរបស់ព្រះជាម្ចាស់ ជាមកុដដ៏រុងរឿង និងជាព្រះមាលារាជ្យ អេសាយ ៦២:៣

៨. សិរីល្អរបស់ព្រះជាម្ចាស់ថ្វាយដល់គ្នាទៅវិញទៅមក — នៅក្នុងព្រះត្រៃឯក

ក. ព្រះជាម្ចាស់ថ្វាយសិរីល្អដល់ព្រះរាជបុត្រា កូល៉ុស ១:១៩ យ៉ូហាន ១៧:៥ខ

ខ. ព្រះរាជបុត្រាថ្វាយសិរីល្អដល់ព្រះវរបិតា យ៉ូហាន ១៧:៤

គ. ព្រះវិញ្ញាណថ្វាយសិរីល្អដល់ព្រះរាជបុត្រា យ៉ូហាន ១៦:១៤

៩. សិរីល្អរបស់ព្រះជាម្ចាស់ថ្វាយដល់គ្នាទៅវិញទៅមក - យើងចូលរួមនៅក្នុងការថ្វាយដល់គ្នាទៅវិញទៅមកនេះ

ក. ស្នាព្រះហស្តដ៏វិសេសដែលព្រះបានបង្កើត លោកុប្បត្តិ ១:៣១

ខ. ព្រះជាម្ចាស់ជាសិរីល្អរបស់យើង អេសាយ ៦០:១៩

គ. យើងជាសិរីល្អរបស់ព្រះជាម្ចាស់ អេសាយ ៦២:៣

ឃ. យើងថ្វាយសិរីល្អដល់ព្រះរាជបុត្រា យ៉ូហាន ១៧:១០

១០. ការបាត់បង់សិទ្ធិកូនច្បង

ក. របស់ដែលបង្កើតមកដើម្បីបង្ហាញ លោកុប្បត្តិ ១:១០២៤

ខ. អ្នកមានរូបចំនឹងអង្គទ្រង់ដើម្បីឆ្លុះបញ្ចាំង និងចូលរួម លោកុប្បត្តិ ១:៣១

គ. ការបាត់បង់សិទ្ធិកូនច្បង លោកុប្បត្តិ ៣:១-៦:៧

១១. ការស្អាងឡើងវិញតាមរយៈសេចក្តីស្រឡាញ់ដែលហ៊ានលះបង់

ក. ការផ្សះផ្សាគ្រប់ទាំងអស់

ខ. ព្រះគុណ - អំណាចអោយមានបំណងចង់ធ្វើ និងប្រព្រឹត្តតាម ភីលីព ២:១៣

គ. ឆ្លុះពីសិរីល្អរបស់ព្រះអង្គខ្លាំងឡើងៗ ២ កូរិនថូស ៣:១៨

ឃ. បង្កើតផលផ្លែច្រើនដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់ យ៉ូហាន ១៥:៨

១២. តើសិរីល្អរបស់ព្រះជាម្ចាស់គឺជាអ្វី?

ក. ទំនាក់ទំនងដែលមានសេចក្តីស្រឡាញ់ និងហ៊ានលះបង់សម្រាប់មនុស្សដទៃទៀត

ខ. នៅក្នុង:

១. ព្រះត្រៃឯក

២. របស់ដែលបានបង្កើតមក

៣. សញ្ញាចាស់ - អ៊ីស្រាអែល

៤. ឈើឆ្កាង

៥. ភាពអស់កល្បជានិច្ច

១៣. មហាបេសកកម្ម ម៉ាកុស ១៦:១៥ ម៉ាថាយ ២៨:១៩

ក. ការប្រកាស - ចូរចេញទៅប្រកាសដំណឹងល្អ

ខ. ការដាំក្រុមជំនុំ - ការធ្វើបុណ្យជ្រមុជទឹក

គ. ចំណេះដឹងបទគម្ពីរ - បង្រៀនគ្រប់ទាំងសេចក្តី

១៤. មហាធ្វេសប្រហែស

ក. ការបង្កើតសិស្ស - បង្រៀនឱ្យកាន់តាម

ខ. លទ្ធផលរបស់មហាធ្វេសប្រហែស

១. ការប្រែចិត្តជឿច្រើន

២. ដាំក្រុមជំនុំបានច្រើន

៣. ការបំផ្លាស់បំប្រែតិចតួច

១៥. ការតាំងអ្នកដែលធ្វេសប្រហែសឡើងវិញ

ក. លក្ខខណ្ឌពីរយ៉ាង:

១. ការបន្ទាបខ្លួន

២. ការប្រែចិត្ត / ការស្តាប់បង្គាប់

ខ. សេចក្តីសន្យាពីរយ៉ាង:

១. ការអត់ទោស

២. ការប្រោសឱ្យជា

១៦. មហាបេសកកម្ម និងការបំផ្លាស់បំប្រែ

ក. ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ - ដាក់ខ្សែធ្នូ ការដាក់គ្រាប់ព្រួញចូលកន្លែង

ខ. ការបង្រៀនអ្វីដែលព្រះយេស៊ូវបានបង្រៀន - ការតម្រង់គោលដៅ ការយឺតគ្រាប់ព្រួញនឹងខ្សែ

គ. ការបង្កើតសិស្សឱ្យស្តាប់បង្គាប់ដោយនៅក្នុងអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ - ការព្រលែងគ្រាប់ព្រួញ

ឃ. ការបាញ់ចំគោលដៅ - ការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ និងធ្វើជាសិរីល្អរបស់ព្រះអង្គ

១៧. តើសិរីល្អរបស់ព្រះជាម្ចាស់មើលទៅមានលក្ខណៈយ៉ាងដូចម្តេចនៅក្នុងយើង?

ក. ចិត្តអាណិតអាសូរជួយស្នងអ្នកដែលខ្វះខាត ម៉ាកុស...

ខ. ស្ម័គ្រចិត្តរងទុក្ខសម្រាប់មនុស្សដទៃ ភីលីព ២:៨

គ. ស្រឡាញ់គ្នាទៅវិញទៅមក កិច្ចការ ៤:៣២

ឃ. ចិត្តសប្បុរសចំពោះ "អ្នកជិតខាង" ២កូរិនថូស ៨:១-១៣

ង. សេចក្តីចៅរ៉ៅ រ៉ូម ១២:១៣ ទីតុស ១:៨ ១ពេត្រុស ៤:៩

ច. សហគមន៍ដែលបានបំផ្លាស់បំប្រែ អេសាយ ៥៨:១០-១២

ឆ. កិច្ចការបម្រើ អេភេសូរ ៤:១២

១៨. កិច្ចការចុងក្រោយមិនមែនៈ

ក. នាំមនុស្សមកឯព្រះគ្រីស្ទ

ខ. ដាំក្រុមជំនុំ

គ. បង្រៀនមនុស្សអំពីអ្វីដែលព្រះយេស៊ូវបានបង្រៀន

១៩. កិច្ចការចុងក្រោយគឺៈ

ក. ធ្វើឱ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានគ្រប់លក្ខណ៍សម្រាប់សិរីល្អរបស់ព្រះជាម្ចាស់

១. ដោយធ្វើឱ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានគ្រប់លក្ខណ៍ដើម្បីធ្វើជាសិរីល្អរបស់ព្រះជាម្ចាស់

២. របៀបណា? ដោយបង្រៀនឱ្យធ្វើតាមគ្រប់ទាំងអស់ដែលព្រះអង្គបានបង្គាប់

២០. តើយើងមើលឃើញសិរីល្អរបស់ព្រះជាម្ចាស់ (ការបម្រើ / សេចក្តីស្រឡាញ់ដែលហ៊ានលះបង់) ដែរឬទេ នៅក្នុងកិច្ចការនេះ

ក. និកាយរបស់យើង?

ខ. ព័ន្ធកិច្ចក្រៅក្រុមជំនុំរបស់យើង?

គ. ក្រុមជំនុំតាមមូលដ្ឋានរបស់យើង?

ឃ. ជីវិតរស់នៅផ្ទាល់ខ្លួនរបស់យើង?

ង. ប្រសិនបើមិនឃើញទេ ពិនិត្យមើលគោលដៅរបស់យើងឡើងវិញ

២១. ព្រះវរបិតានៃយើងខ្ញុំ

២២. ភាពទន់ខ្សោយនៃការហ្វឹកហ្វឺននៅពេលបច្ចុប្បន្ន

ក. ភាពបរិសុទ្ធផ្ទាល់ខ្លួន

ខ. ចំណេះដឹងបទគម្ពីរ

គ. ការបណ្តុះបណ្តាលនៅក្នុងការផ្សាយដំណឹងល្អ / ការដាំក្រុមជំនុំ

ឃ. គ្មានការហ្វឹកហ្វឺនសម្រាប់ការស្តាប់បង្គាប់

២៣. គោលការណ៍ទី ១

ក. ការពឹងអាងលើព្រះគុណដែលជួយឱ្យអាចធ្វើបាន

ខ. នៅជាប់នឹងខ្ញុំ និងកាន់តាមបញ្ញត្តិខ្ញុំ...យ៉ូហាន ១៥:៧-៨

២៤. គោលការណ៍ទី ២

ក. សេចក្តីសុចរិត និងកាធ្វើជាគំរូ

ខ. អ្នកណាដែលកាន់តាម ហើយបង្រៀន...ម៉ាថាយ ៥:១៩ (កាន់តាមមុនបង្រៀន)

២៥. គោលការណ៍ទី ៣

ក. ការបន្តបង្រៀន (រួមមានការប្រែចិត្តតាមដែលត្រូវការ)

ខ. ទឹកដោះទៅអាហាររឹង ដោយបរិភោគជាដរាប ហេព្រើរ ៥:១៤

គ. គំរូជាដរាប កិច្ចការ ២០:៣៥

២៦. គោលការណ៍ទី ៤

ក. ការអនុវត្តន៏

ខ. បង្ហាញសេចក្តីស្រឡាញ់តាមរយៈការប្រព្រឹត្តិរបស់យើង ១យ៉ូហាន ៣:១៨-១៩

២៧. គោលការណ៍ទី ៥

ក. ការទទួលខុសត្រូវ

ខ. ពួកគេបានប្រាប់ពីគ្រប់ការទាំងអស់ កិច្ចការ ១៥:៤

២៨. គោលការណ៍ទី ៦

ក. ការលើកទឹកចិត្ត

ខ. លើកទឹកចិត្តគ្នាទៅវិញទៅមក ១ថែស្សាឡូនីច ៥:១១

២៩. គោលការណ៍ទី ៧

ក. ការអបអរ

ខ. ព្រមគ្នាលើកព្រះនាមទ្រង់ឡើង ទំនុកដំកើង ៣៤:៣

៣០. សង្ខេបមេរៀន

៣១. រឿងពីប្រទេសអ៊ូហ្កាន់ដា

ក. ការប្រាប់ដោយប្រយោលទី ១

១. រក្សាការផ្ដោតអារម្មណ៍របស់យើងលើគោលដៅ

ខ. ការប្រាប់ដោយប្រយោលទី ២

១. កសាងការបង្កើតសិស្សនៅលើគោលការណ៍ និងការអនុវត្តន៍ដែលហ្វឹកហ្វឺនសម្រាប់ការស្ដាប់បង្គាប់

គ. ការប្រាប់ដោយប្រយោលទី ៣

១. វាយតម្លៃ មិនមែនតាមចំនួនទេ ប៉ុន្តែ...

២. តាមរយៈភស្តុតាងពីសិរីល្អរបស់ព្រះជាម្ចាស់ (ការស្ដាប់បង្គាប់) នៅក្នុងសិស្សរបស់លោកអ្នក

# គោលដៅរបស់យើង ~ សិរីរុងរឿងរបស់ព្រះជាម្ចាស់

## មេរៀន

កាលពីខែវិច្ឆិកាមុន ខ្ញុំកំពុងតែនិយាយទៅកាន់អ្នកដឹកនាំពួកជំនុំមួយក្រុមដើមកំណើតឥណ្ឌានៅប្រទេសប្រេស៊ីល ប៉ែកអគ្នេយ៍។ ខ្ញុំបានសួរពួកគេថាតើពួកគេគិតថា ដំណឹងល្អគួរតែនាំឱ្យមានការបំផ្លាស់បំប្រែបុគ្គល គ្រួសារ និងសហគមន៍ដែរឬយ៉ាងណា។ ពួកគេបានយល់ព្រមថា ដំណឹងល្អគួរតែនាំឱ្យមានការបំផ្លាស់បំប្រែ។ បន្ទាប់មក ខ្ញុំបានសួរថាតើពួកគេបានសង្កេតឃើញថា ការរីកសាយភាយនៃដំណឹងល្អនៅក្នុងកុលសម្ព័ន្ធរបស់ពួកគេបាននាំមកនូវការបំផ្លាស់បំប្រែបែបដែលពួកគេបានរំពឹងទុកដែរឬអត់។ ពួកគេបានឆ្លើយយ៉ាងច្បាស់ថា "ទេ"។

នៅលើជញ្ជាំងបន្ទប់ដែលខ្ញុំកំពុងបង្រៀន មានព្យួរធ្នូរ និងគ្រាប់ព្រួញមកពីកុលសម្ព័ន្ធមួយ។ ខ្ញុំបានយកធ្នូរ និងគ្រាប់ព្រួញនោះមក ហើយសួរថាតើមានអ្នកចម្បាំងវ័យក្មេងដែលចេះប្រើរបស់ទាំងនេះដែរឬទេ។ មានដៃជាច្រើនបានលើកឡើង ហើយខ្ញុំបានហៅអ្នកស្ម័គ្រចិត្តម្នាក់ពីក្នុងចំណោមពួកគេឡើងមក។ នៅពេលដែលអ្នកនោះបានឡើងមកខាងមុខ ខ្ញុំបានសួរគាត់ថា គាត់អាចបាញ់គ្រាប់ព្រួញដែលខ្ញុំកំពុងកាន់ឱ្យចំគោលដៅដែលខ្ញុំនឹងជ្រើសរើសបានដែរឬអត់ គាត់បានអះអាងថា គាត់អាចធ្វើបាន។ បន្ទាប់មក ខ្ញុំបានប្រាប់គាត់ និងសិស្សថា ខ្ញុំចង់ពិសោធន៍។

ខ្ញុំបានទាញកន្សែងមួយចេញពីកាតាបស្ពាយរបស់ខ្ញុំមក ហើយចង់ជុំវិញភ្នែករបស់គាត់។ បន្ទាប់មក ខ្ញុំបានប្រាប់គោលដៅទៅសិស្សដែលកំពុងរង់ចាំមើល គឺជាកន្លែងមួយនៅលើជញ្ជាំងដែលនៅចំពីក្រោយខ្ញុំ។ បន្ទាប់មក ខ្ញុំបានសូមអ្នកស្ម័គ្រចិត្តដែលចងភ្នែកនោះឱ្យបាញ់ចំគោលដៅ។ គាត់បានប្រកែកថា គាត់មិនអាចមើលឃើញគោលដៅបានទេ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំចង់ឱ្យគាត់តម្រង់ព្រួញទៅទិសដែលគាត់ជឿថាជាគោលដៅ។ លើកទីមួយ គាត់បានតម្រង់ចំសិស្សដែលនាំគ្នាដកដង្ហើមភ័យ! ខ្ញុំបានប្រាប់គាត់ឱ្យឈប់ ហើយសាកល្បងម្តងទៀត។ លើកនេះ គាត់បានតម្រង់ទៅរកទិសគោលដៅ ប៉ុន្តែឆ្ងាយដែលគាត់មិនអាចបាញ់ចំគោលដៅបានឡើយ ប្រសិនបើគាត់ព្រលែងគ្រាប់ព្រួញទៅ។ បន្ទាប់មក ខ្ញុំបានដោះកន្សែងរុំភ្នែកចេញ ហើយប្រាប់ឱ្យសិស្សដែលអង្គុយមើលចង្អុលប្រាប់គោលដៅ។ ពួកគេបានប្រាប់។ អ្នកស្ម័គ្រចិត្តរបស់ខ្ញុំរអ៊ូរទាំម្តងទៀតថា *ប្រសិនបើគាត់មិនអាចមើលឃើញគោលដៅបានផង គាត់មិនអាចបាញ់ចំគោលដៅបានទេ*។

ក្រោយពីយុវជនស្ម័គ្រចិត្តរបស់ខ្ញុំបានអង្គុយចុះរួចហើយ ខ្ញុំបានពន្យល់ថា រូបភាពនេះអាចឆ្លុះបញ្ចាំងឱ្យឃើញពីមូលហេតុដែលការខិតខំប្រឹងប្រែងរបស់យើងនៅក្នុងការផ្សាយដំណឹងល្អ និងការដាំពួកជំនុំមិនបាននាំឱ្យមានការបំផ្លាស់

បំប្រែដែលយើងរំពឹងចង់បានពីដំណឹងល្អដែលយើងប្រកាស ។ ខ្ញុំបានប្រាប់ថា យើងមិនបានឃើញការបំផ្លាស់បំប្រែដែលយើងសង្ឃឹមចង់បាននៅក្នុងបុគ្គល គ្រួសារ និងសហគមន៍ នៅពេលដែលយើងជោគជ័យនៅក្នុងការផ្សាយដំណឹងល្អ និងការដាំពូកជំនុំ ពីព្រោះយើងបានយល់ច្រឡំអំពី*គោលដៅ*គឺជាភារកិច្ចដែលព្រះគ្រីស្ទបានប្រទានឱ្យយើង ។

## គោលដៅគឺជាសិរីល្អរបស់ព្រះជាម្ចាស់

ពាក្យ សិរីល្អ ត្រូវបានប្រើជាងបីរយដងនៅក្នុងព្រះគម្ពីរ ។ ភាគច្រើនយោងទៅរកសិរីល្អរបស់ព្រះជាម្ចាស់ ។ ដើម្បីយល់អ្វីដែលសិរីល្អរបស់ព្រះជាម្ចាស់អាចមានន័យ និងគួរតែមានន័យសម្រាប់យើង យើងត្រូវមើលម្តងទៀតពីមហាបេសកកម្មរបស់យើងតាមរយៈមហាបេសកកម្ម ។ ដំបូង ចូរពិនិត្យមើលបរិបទ*ចក្រវាឡ*របស់មហាបេសកកម្ម ។ បរិបទនេះគឺជាសិរីល្អរបស់ព្រះជាម្ចាស់ដែលត្រូវបានបង្ហាញនៅក្នុងរបស់ដែលត្រូវបានបង្កើតមក ។ ស្តេចដាវីឌបានរំលឹកយើងថា ចក្រវាឡប្រកាសសិរីល្អរបស់ព្រះជាម្ចាស់ ។ តើចក្រវាឡប្រកាសសិរីល្អរបស់ព្រះអង្គយ៉ាងដូចម្តេច? នៅគ្រប់កម្រិតទាំងអស់!

នៅជិតផ្ទះរបស់យើង មានប្រដាប់ឆ្លុះមើលពិភពលោកយ៉ាងធំមួយ ។ គ្រប់ពេលដែលខ្ញុំទៅលេងសារៈមន្ទីរមើលលំហនោះ ខ្ញុំស្ញប់ស្ញែងនឹងទំហំដែលគ្មានដែនកំណត់របស់ចក្រវាឡ ។ នៅលើផែនដី យើងសម្លឹងមើលដោយស្ញប់ស្ញែងពីសិរីល្អរបស់ថ្ងៃលិច ។ នៅកម្រិតភាគល្អិត យើងស្ញប់ស្ញែងនឹងទំនាក់ទំនងយ៉ាងស្មុគស្មាញរបស់ម៉ូលេគុលដែលទ្រទ្រង់ជីវិត ។ មែនហើយ ស្តេចដាវីឌមានបន្ទូលត្រឹមត្រូវណាស់:

"ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ
ហើយលំហអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ
ថ្ងៃ១ពោលប្រាប់ដល់ថ្ងៃ១ទៀត
ហើយយប់១ក៏សំដែងចំណេះដល់យប់១ទៀតដែរ
ឯពាក្យសំដី ឬភាសា នោះគ្មានឮឡើយ
គ្មានអ្នកណាដែលឮសំឡេងនៃរបស់ទាំងនោះទេ
ប៉ុន្តែដំណឹងដែលរបស់ទាំងនោះផ្សាយមកក៏បានចេញទៅគ្រប់លើផែនដី
ហើយសេចក្តីនោះបានឮទៅដល់ទីបំផុតលោកីយ"
(ទំនុកដំកើង ១៩:១-៤)

បទគម្ពីរបង្ហាញប្រាប់ថា គោលបំណងពិតប្រាកដរបស់ព្រះជាម្ចាស់គឺបង្ហាញសិរីល្អរបស់ព្រះជាម្ចាស់ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញពីអត្តចរិតយ៉ាងអស្ចារ្យក្រៃលែងរបស់ព្រះអង្គ។ សិរីល្អគឺជាលក្ខណៈមួយដែលត្រូវបានប្រទានមកដើម្បីឱ្យបានទទួលស្គាល់ភាពធំឧត្តម ភាពស័ក្តិសម ព្រះកិត្តិយស ភាពខុសប្លែក សោភ័ណភាព ព្រះតេជៈ និងភាពរុងរឿង។ ស៊ី អេស ឡឺវីស ប្រៀបប្រដូចសិរីល្អទៅនឹងទម្ងន់។ នៅពេលដែលខ្ញុំគិតដល់សិរីល្អរបស់ *ព្រះជាម្ចាស់* មានពាក្យច្រើនថែមទៀតផុសឡើងនៅក្នុងគំនិត ដូចជាភាពបរិសុទ្ធ យុត្តិធម៌ ព្រះហឫទ័យមេត្តាករុណា ព្រះហឫទ័យអត់ធ្មត់ កំឡាំងគ្មានដែនកំណត់ និងសេចក្តីស្រឡាញ់ស្ម័គ្រចិត្ត និងហ៊ានលះបង់។ យើងត្រូវការលក្ខណៈទាំងនេះខ្លាំងណាស់នៅក្នុងពិភពលោកដែលខ្ទេចខ្ទាំរបស់យើង។

បើពុំមានការយល់ដឹងស្របតាមព្រះគម្ពីរអំពីភាពទាក់ទាញយ៉ាងអស្ចារ្យនៃសិរីល្អរបស់ព្រះជាម្ចាស់ទេ គោលដៅនៃសិរីល្អរបស់ព្រះអង្គអាចត្រូវបានបកស្រាយខុសថាជាអំនួតរបស់អ្នកគ្រប់គ្រងដែលទាមទារឱ្យប្រជាជនថ្វាយបង្គំខ្លួន ប៉ុន្តែនៅពេលដែលយើងយល់អំពីសិរីល្អរបស់ព្រះជាម្ចាស់ចេញពីទស្សនៈដែលត្រូវបានបើកសំដែងឱ្យឃើញនៅក្នុងព្រះគម្ពីរ យើងមើលឃើញសិរីល្អរបស់ព្រះជាម្ចាស់នៅក្នុងពន្លឺផ្សេងទាំងស្រុង។ សិរីល្អរបស់ព្រះជាម្ចាស់គួរឱ្យស្រឡាញ់ខ្លាំងណាស់ មានការការពារខ្លាំងណាស់ លះបង់ខ្លាំងណាស់ បរិសុទ្ធខ្លាំងណាស់ គ្មានការបោកបញ្ឆោតទាល់តែសោះ ដែលនៅពេលដែលយើងជួបសិរីល្អរបស់ព្រះអង្គ យើងចង់នៅជិតតាមដែលអាចធ្វើបាន។

នៅពេលដែលខ្ញុំសរសេរ ម៉ាស៊ីនចាក់បទចម្រៀងមួយនៅឯព័ន្ធកិច្ចមួយនៅក្បែរនោះ ចាក់បទទំនុកដំកើងនិពន្ធដោយ ចូកឈីន នានឌឺ (១៨៦៣)។ ពាក្យដំបូងៗដែលហូរកាត់គំនិតរបស់ខ្ញុំគឺ "ចូរសរសើរព្រះអម្ចាស់ ជាព្រះដែលមានតេជៈ ជាស្តេចលើរបស់ដែលបានបង្កើតមក អូហ៍ ព្រលឹងរបស់ខ្ញុំអើយ ចូរសរសើរតម្កើងព្រះអង្គ ពីព្រោះព្រះអង្គគឺជាសុខភាពរបស់អ្នក និងជាសេចក្តីសង្គ្រោះរបស់អ្នក"។

## ការឆ្លុះបញ្ចាំងសិរីល្អរបស់ព្រះជាម្ចាស់

ដូចជាលោកខែឆ្លុះបញ្ចាំងពន្លឺរបស់ថ្ងៃ របស់ដែលបានបង្កើតមកគ្រាន់តែជាការឆ្លុះបញ្ចាំងសិរីល្អរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ សាកល្បងស្រមៃមើលមួយភ្លែតថា ការមើលចំសិរីល្អរបស់ព្រះជាម្ចាស់នឹងទៅជាយ៉ាងណា។ នោះដូចជាការមើលចំថ្ងៃ។ លោកអេសាយបានមើលចំសិរីល្អរបស់ព្រះជាម្ចាស់នៅក្នុងនិមិត្ត។ នៅក្នុងរូបភាពនេះ (អេសាយ ៦) សិរីល្អរបស់ព្រះជាម្ចាស់ត្រូវបានពណ៌នាថាជាភាពបរិសុទ្ធ។ នៅក្នុងការមើលឃើញសិរីល្អនោះ លោកអេសាយបានដួលផ្កាប់មុខដូចជាមនុស្សស្លាប់។ ប្រសិនបើយើងព្យាយាមស្រមៃមើលសិរីល្អរបស់ព្រះជាម្ចាស់ យើងមិនអាចទេ។ សិរីល្អ

របស់ព្រះអង្គលើសហួសពីសមត្ថភាពរបស់យើង។ ប៉ុន្តែ អស្ចារ្យណាស់ ព្រះជាម្ចាស់បានបង្កើតមនុស្សមកដើម្បីឆ្លុះបញ្ចាំងសិរីល្អរបស់ព្រះអង្គ!

ព្រះជាម្ចាស់ចង់ឱ្យប្រជារាស្ត្ររបស់ព្រះអង្គ គឺអ៊ីស្រាអែល ធ្វើជាសង្ឃដល់សាសន៍ទាំងឡាយដែលនៅជុំវិញពួកគេ ដោយរស់នៅតាមរបៀបមួយដែលសាសន៍ដទៃនឹងមើលឃើញសិរីល្អរបស់ព្រះអង្គ ហើយទាញពួកគេមកឯព្រះអង្គ (ចោទិយកថា ៤:៥-៨)។ នៅត្រឹមកម្រិតបុគ្គល ព្រះយេស៊ូវបានប្រាប់អ្នកដើរតាមព្រះអង្គឱ្យពន្លឺរបស់ពួកគេបានភ្លឺឡើង ដើម្បីឱ្យអ្នកដែលឃើញ នឹងថ្វាយសិរីល្អដល់ព្រះជាម្ចាស់ (ម៉ាថាយ ៥:១៣-១៦)។

លោកប៉ុលរំលឹកយើងបីដងថា យើងត្រូវ*ធ្វើជា*សិរីល្អរបស់ព្រះជាម្ចាស់។ នៅក្នុងអេភេសូរ ១ លោកនិយាយថា យើងត្រូវបានព្រះទទួលជាកូនចិញ្ចឹម "ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់" (ខ ៦)។ នៅក្នុង ខ ១១ និងខ ១២ លោកប្រាប់យើងថា យើងត្រូវបានជ្រើសរើសមកសម្រាប់នឹងសរសើរដល់សិរីល្អទ្រង់។ ដើម្បីឱ្យប្រាកដថា យើងយល់សេចក្ដីដ៏អស្ចារ្យនេះ លោកប៉ុលប្រាប់យើងថា យើងត្រូវបានដៅចំណាំសម្រាប់ការប្រោសលោះ "សម្រាប់ជាសេចក្ដីសរសើរដល់សិរីល្អនៃទ្រង់" (ខ ១៣ និង ខ ១៤)។ នៅកន្លែងផ្សេងទៀត លោកប៉ុលប្រាប់យើងឱ្យធ្វើគ្រប់ការទាំងអស់សម្រាប់ចំរើនសិរីល្អដល់ព្រះ (១ កូរិនថូស ១០:៣១)។ លោកពេត្រុសបាននិយាយថា ចូររស់នៅឱ្យអ្នកដែលសង្កេតមើលយើង គេថ្វាយសិរីល្អដល់ព្រះជាម្ចាស់ (១ ពេត្រុស ២:១១-១២)។

និយាយបានម្យ៉ាងទៀតគឺថា នៅពេលដែលយើងរស់នៅតាមរបៀបដែលព្រះជាម្ចាស់ប្រាប់ យើងថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ ហើយ ព្រះជាម្ចាស់*គឺជា*សិរីល្អរបស់យើង។ លោកអេសាយបានសរសេរថា "ព្រះយេហូវ៉ា ទ្រង់នឹងជាពន្លឺដ៏នៅអស់កល្បជានិច្ចដល់ឯងវិញ ហើយព្រះនៃឯងនឹងជាសិរីល្អដល់ឯងដែរ" (អេសាយ ៦០:១៩)។ មានច្រើនទៀត! នៅពេលដែលយើងរស់នៅតាមរបៀបដែលព្រះជាម្ចាស់បានបង្កើតយើងមកឱ្យរស់នៅ យើង*ក្លាយជា*សិរីល្អរបស់ព្រះជាម្ចាស់។ លោកអេសាយបាននិយាយថា "ឯងនឹងជាមកុដដ៏រុងរឿងនៅព្រះហស្តនៃព្រះយេហូវ៉ា ហើយជាព្រះមាលារាជ្យនៅព្រះហស្តរបស់ព្រះនៃឯង" (អេសាយ ៦២:៣)។ សិរីល្អរបស់ព្រះជាម្ចាស់មានលក្ខណៈទៅវិញទៅមក។ អស្ចារ្យខ្លាំងណាស់!

សិរីល្អមានលក្ខណៈជាវដ្ដនេះគឺជាការឆ្លុះបញ្ចាំងពីសេចក្ដីស្រឡាញ់ដែលលះបង់របស់ព្រះត្រៃឯក ដែលត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងកូល៉ុស ១:១៥-២០ យ៉ូហាន ១៦:១៣-១៤ និងយ៉ូហាន ១៧:៤-១០។ ព្រះវិញ្ញាណបរិសុទ្ធថ្វាយសិរីល្អដល់ព្រះយេស៊ូវ។ ព្រះយេស៊ូវថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ថ្វាយសិរីល្អដល់ព្រះយេស៊ូវ។ យើងថ្វាយសិរីល្អដល់ព្រះយេស៊ូវ ហើយចេះតែបន្តទៅៗ។

ខ្ញុំជឿថា មូលហេតុដែលព្រះជាម្ចាស់បានផ្លាស់ប្តូរការវាយតម្លៃរបស់ព្រះអង្គមកលើស្នាព្រះហស្តរបស់ព្រះអង្គពី "ល្អ" (លោកុប្បត្តិ ១:១-២៤) ទៅជា "ល្អប្រពៃ" (លោកុប្បត្តិ ១:៣១) គឺថា ព្រះជាម្ចាស់បានបង្កើតស្នាព្រះហស្តដ៏វិសេសរបស់ព្រះអង្គ គឺមនុស្ស។ មនុស្សមានសមត្ថភាពដើម្បីឆ្លុះបញ្ចាំងសិរីល្អរបស់ព្រះអង្គលើសជាងស្នាព្រះហស្តផ្សេងទៀត។ តើមនុស្សអាចធ្វើកិច្ចការនោះបានយ៉ាងដូចម្តេច? យើងធ្វើកិច្ចការនោះ នៅពេលដែលយើងឆ្លុះបញ្ចាំងរូបអង្គទ្រង់នៅក្នុងការមើលថែស្នាព្រះហស្តរបស់ព្រះអង្គ រួមបញ្ចូលទាំងការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ តាមរយៈការយកចិត្តទុកដាក់នេះ យើងពង្រីកការស្គាល់សិរីល្អរបស់ព្រះជាម្ចាស់ រហូតដល់ "គ្រប់ទាំងអស់នឹងស្គាល់ព្រះយេហូវ៉ានៅពេញពាសលើផែនដី ដូចជាទឹកនៅពេញពាសក្នុងសមុទ្រដែរ" (អេសាយ ១១:៩)។ ទេវវិទូជាច្រើនហៅការនេះថា "បញ្ញត្តិខាងវប្បធម៌"។

អំពើបាបរបស់មនុស្សបានបំផ្លាញនិមិត្តនេះ គឺគោលបំណងនេះរបស់ព្រះជាម្ចាស់ ប៉ុន្តែព្រះគ្រីស្ទបានស្តារសិទ្ធិកូនច្បងរបស់យើងឡើងវិញ គឺការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ដែលព្រះអង្គសព្វព្រះហឫទ័យចង់ឱ្យយើងធ្វើ។ លោកប៉ុលបានពង្រឹងសេចក្តីពិតនេះឡើងវិញនៅក្នុងកូល៉ុស ១:១៥-២០ នៅពេលដែលលោកបានសង្ខេបផែនការរបស់ព្រះជាម្ចាស់ក្នុងការដោះស្រាយអំពើបាប និងជួយយើងឱ្យអាចចូលរួមម្តងទៀតនៅក្នុងគោលបំណងរបស់ព្រះអង្គសម្រាប់ចក្រវាឡ: "ហើយឱ្យបានផ្សះផ្សាគ្រប់ទាំងអស់ឱ្យជានឹងអង្គទ្រង់ ដោយសារព្រះរាជបុត្រានោះ ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្តី ទាំងតាំងស្ពានមេត្រី ដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់"។

ដោយព្រោះតែឈើឆ្កាង យើងជាមនុស្សអាចទទួលបានសិទ្ធិកូនច្បងរបស់យើងមកវិញក្នុងការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ តាមរយៈការរស់នៅដូចដែលព្រះអង្គបានចង់ឱ្យយើងរស់នៅ និង<u>*នៅតែចង់ឱ្យយើងរស់នៅ*</u>។ អេសាយ ៥៨ ប្រាប់យើងថា ការរស់នៅតាមរបៀបដែលព្រះអង្គចង់ឱ្យយើងរស់នៅគឺជាការថ្វាយបង្គំដ៏ពិត។ ឈើឆ្កាងតំណាងឱ្យព្រះគុណ គឺជាការសព្វព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះយើងដែលយើងមិនសមនឹងទទួលបាន។ ប៉ុន្តែ ព្រះគុណនេះលើសជាងការសព្វព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលយើងមិនសមនឹងទទួលបានទៅទៀត។ ព្រះគុណនេះគឺជាការជួយឱ្យអាចស្គាល់របៀបដែលព្រះជាម្ចាស់ត្រាស់ហៅយើងឱ្យរស់នៅ និងជាកំឡាំងយ៉ាងអស្ចារ្យដើម្បីធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ដោយថ្វាយសិរីល្អដល់ព្រះជាម្ចាស់តាមរយៈរបៀបដែលយើងរស់នៅ (ភីលីព ២:១៣)។ នៅពេលដែលយើងថ្វាយសិរីល្អដល់ព្រះជាម្ចាស់តាមរយៈការរស់នៅដោយសុចរិត យើង<u>*គឺជា*</u>សិរីល្អរបស់ព្រះអង្គ! សេចក្តីពិតនេះត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញផងដែរនៅក្នុង ២ កូរិនថូស ៣:១៨ "ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់...យើងកំពុងតែផ្លាស់ប្រែទៅឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារ

ព្រះអម្ចាស់..."។ យ៉ូហាន ១៥:៨ ប្រាប់យ៉ាងសាមញ្ញថា "ព្រះវរបិតាខ្ញុំបានដំកើងឡើង ដោយសេចក្ដីនេះឯង គឺដោយអ្នករាល់គ្នាបង្កើតផលជាច្រើន"។

## សិរីល្អរបស់ព្រះជាម្ចាស់ និងមហាបេសកកម្ម

នៅក្នុងជំនឿដំណឹងល្អរបស់យើង យើងបានបែកចេញពីការប្រាប់ដោយប្រយោលដ៏ពោរពេញដែលកើតចេញពីការយល់ដឹងអំពីគោលបំណងពិតប្រាកដរបស់ព្រះជាម្ចាស់។ យើងបានសិក្សាមហាបេសកកម្ម និងមានការប្រុងប្រយ័ត្ននៅក្នុងការអនុវត្តន៍សេចក្ដីបង្គាប់ឱ្យផ្សាយដំណឹងល្អ និងដាំក្រុមជំនុំ។ ប៉ុន្តែ យើងបានទៅខុសគោលដៅ ឬគោលបំណងពិតប្រាកដនោះ។ ដោយព្រោះយើងបានទៅខុសគោលដៅ ខ្ញុំនិយាយថា យើងក៏បានទៅខុសលទ្ធផលដែលព្រះជាម្ចាស់ចង់បានដែរ គឺការបំផ្លាស់បំប្រែ ឬការប្រោសទឹកដីរបស់យើងឱ្យបានជា។

សូមយើងមើលមហាបេសកកម្មដោយយកចិត្តទុកដាក់។ នេះមិនមែនជាការសិក្សាផ្នែកនិមួយៗនៃមហាបេសកកម្មទេ ប៉ុន្តែយើងនឹងមើលមហាបេសកកម្មចេញពីទស្សនៈរបស់ពួកជំនុំដំណឹងល្អទូទៅ។ សេចក្ដីយោងចម្បងទៅរកសេចក្ដីបង្គាប់ចុងក្រោយរបស់ព្រះយេស៊ូវដល់ពួកអ្នកដើរតាមព្រះអង្គមាននៅក្នុងម៉ាកុស ១៦:១៥ និងម៉ាថាយ ២៨:១៩។ នៅក្នុងបទគម្ពីរទាំងនេះ អ្នកជឿរកឃើញការសង្កត់ធ្ងន់ខាងក្រោមនេះ:

១. ការផ្សាយដំណឹងល្អ: "ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងលោកិយទាំងមូល ហើយផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ" (ម៉ាកុស ១៦:១៥)។ "ដូច្នេះ ចូរទៅ*បញ្ចុះបញ្ចូលអោយមានសិស្ស*នៅគ្រប់ទាំងសាសន៍" (ម៉ាថាយ ២៨:១៩)។ (អក្សរទ្រេតត្រូវបានដាក់ថែមចូលមក ហើយនឹងពិភាក្សានៅខាងក្រោមនេះ នៅក្នុង #៤)។

២. ដាំក្រុមជំនុំ: "ព្រមទាំងធ្វើបុណ្យជ្រមុជទឹកអោយដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ" (ម៉ាថាយ ២៨:១៩)។

៣. ការបង្រៀន: "ហើយបង្រៀន" (ម៉ាថាយ ២៨:១៩)។

៤. ការបង្កើតសិស្ស: "អោយគេកាន់តាមគ្រប់ទាំងសេចក្ដីដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង" (ម៉ាថាយ ២៨:១៩)។

នៅក្នុង #១ ខាងលើ យើងមើលឃើញមហាបេសកកម្មរបស់ព្រះគ្រីស្ទឱ្យចេញទៅក្នុងពិភពលោកផ្សាយដំណឹងល្អ និងមើលឃើញមនុស្សត្រូវបានសង្គ្រោះចេញពីស្ថាននរក និងបានទៅស្ថានសួគ៌។ យើងជាអ្នកជឿពូកែសម្រេចផ្នែកនេះនៅក្នុងមហាបេសកកម្មរបស់ព្រះយេស៊ូវ។

នៅក្នុង #២ យើងអានថា យើងត្រូវធ្វើបុណ្យជ្រមុជទឹកឱ្យអ្នកជឿថ្មី ជាសញ្ញាដៅចំណាំពួកគេមកក្នុងរូបកាយរបស់ព្រះគ្រីស្ទ គឺជាពួកជំនុំ។ ការប្រាប់ដោយប្រយោលរបស់ផ្នែកនេះគឺជាការប្រមូលផ្តុំអ្នកជឿទៅជាក្រុមមួយ ហៅថាក្រុមជំនុំមូលដ្ឋាន។ និយាយបានម្យ៉ាងទៀតថា ការធ្វើបុណ្យជ្រមុជទឹកអាចត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការដាំក្រុមជំនុំមូលដ្ឋាន។ យើងជាអ្នកឆេះឆួលក្នុងដំណឹងល្អពូកែសម្រេចផ្នែកនេះនៅក្នុងមហាបេសកកម្មរបស់ព្រះយេស៊ូវ។

នៅក្នុង #៣ យើងមើលឃើញចំណុចខ្លាំងមួយផ្សេងទៀតរបស់អ្នកជឿ។ អ្នកឆេះឆួលក្នុងដំណឹងល្អបានទទួលស្គាល់សារៈសំខាន់នៃការបង្រៀនមនុស្សអំពីជំនឿរបស់យើង។ និកាយ និងព័ន្ធកិច្ចក្រៅក្រុមជំនុំរាប់ពាន់បានសរសេរមេរៀនអំពីការបង្កើតសិស្ស ប៉ុន្តែមេរៀននោះភាគច្រើនប្រៀបបីដូចជាសេចក្តីអធិប្បាយថ្ងៃអាទិត្យ គឺមិនបានធ្វើឱ្យមានការខុសប្លែកខ្លាំងនៅក្នុងរបៀបដែលអ្នកដើរតាមព្រះយេស៊ូវមានទំនាក់ទំនងជាមួយរបស់ដែលបានបង្កើតមក និងជាមួយគ្នាទេ។

លោកអ្នកប្រហែលជាឆ្ងល់ថាហេតុអ្វីបានជាខ្ញុំបំបែក "ហើយបង្រៀន"នៅក្នុង#៣ ចេញពី "អោយគេកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង"នៅក្នុង#៤។ ខ្ញុំបានធ្វើយ៉ាងដូច្នេះ ពីព្រោះទោះបីយើងជាអ្នកឆេះឆួលក្នុងដំណឹងល្អដឹងថា នេះគឺជាផ្នែកមួយរបស់មហាបេសកកម្មក៏ដោយ យើងមិនបានខំប្រឹងប្រែងឱ្យបានស័ក្តិសមនៅក្នុងការបង្រៀនមនុស្សឱ្យស្តាប់បង្គាប់ ឬអនុវត្តអ្វីដែលព្រះយេស៊ូវបានបង្រៀនទេ។ យើងបានធ្លាក់ទៅក្នុងអន្ទាក់ដែលជឿថា ចំណេះដឹងនាំទៅរកការផ្លាស់ប្តូរអាកប្បកិរិយា។ គំនិតដែលជឿថា ការអប់រំល្អនឹងបង្កើតសង្គមដែលត្រឹមត្រូវនោះគឺជាការឆ្លុះបញ្ចាំងឱ្យឃើញពីការកុហករបស់លោកិយនេះ។ គំនិតបង្កើតលទ្ធផល លុះត្រាតែគំនិតនោះយកមកអនុវត្ត។ ក្នុងនាមជាអ្នកឆេះឆួលក្នុងដំណឹងល្អ យើងមានទំនោរគិតថា នៅពេលដែលមនុស្សបំពេញគំនិតរបស់ពួកគេឱ្យបានពេញដោយបទគម្ពីរ ពួកគេនឹងត្រូវបានបំផ្លាស់បំប្រែ។

ផ្នែកចុងក្រោយរបស់មហាបេសកកម្ម (#៤) ជាញឹកញាប់គឺជាចំណុចដែលបាត់នៅក្នុងការឆ្លើយតបរបស់យើងចំពោះសេចក្តីបង្គាប់របស់ព្រះយេស៊ូវ! ផ្នែកដទៃទៀតរបស់មហាបេសកកម្មមានសារៈសំខាន់ ប៉ុន្តែប្រសិនបើយើងមិនបានបង្រៀនអំពីការស្តាប់បង្គាប់ទេ គោលបំណងរបស់ព្រះគ្រីស្ទសម្រាប់អ្នកដើរតាមព្រះអង្គ គឺជាពួកជំនុំត្រូវបានធ្វើឱ្យចុះខ្សោយយ៉ាងធ្ងន់ធ្ងរ។ យើងប្រហែលជាស្គាល់ច្បាស់អំពីឈើឆ្កាង និងតង្វាយឱ្យធួននឹងបាប យើងប្រហែលជាប៉ះពាល់ចិត្តយ៉ាងខ្លាំងដោយសារតែការអត់ទោសដែលយើងបានទទួល ដោយព្រោះតែតង្វាយរបស់ព្រះគ្រីស្ទ។ ប៉ុន្តែ

ប្រសិនបើការដឹងនោះមិនបាននាំយើងឱ្យហ៊ានលះបង់ស្តាប់បង្គាប់ទេ នោះសេចក្តីពិតដ៏សំខាន់នេះនឹងមានលទ្ធផលមើលឃើញច្បាស់នឹងភ្នែកតិចតួចណាស់ ។

ខ្ញុំមានអភ័យឯកសិទ្ធិនឹងបង្រៀនគ្រូគង្វាលនៅកន្លែងសិក្ខាសាលា និងសិស្សនៅក្នុងសាលាព្រះគម្ពីរនៅជុំវិញពិភពលោក ។ ជាញឹកញាប់ ខ្ញុំសុំឱ្យសិស្សនិយាយមហាបេសកកម្មតាមពាក្យរបស់ពួកគេ ។ ជាញឹកញាប់ ពួកគេលើកឡើងផ្នែកចេញទៅ ផ្សាយដំណឹងល្អ ធ្វើបុណ្យជ្រមុជទឹក ដាំពួកជំនុំ និងបង្រៀន ។ គួរឱ្យសោកស្តាយ ពួកគេបាត់ផ្នែកដ៏សំខាន់មួយៈ បង្រៀនមនុស្សឱ្យស្តាប់បង្គាប់តាមសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ ។ មិនគួរឱ្យភ្ញាក់ផ្អើលទេដែលផ្នែកនេះកំពុងតែបាត់ជាញឹកញាប់ផងដែរនៅក្នុងនិកាយ និងព័ន្ធកិច្ចក្រៅក្រុមជំនុំរបស់ពួកគេ ។

ចន សេកឃី ប្រធានក្រុមទេវសាស្ត្រនៅក្នុងចក្រភពអង់គ្លេស បាននិយាយនៅក្នុង*សារព័ត៌មានទេវសាស្ត្រ* ដែលចេញផ្សាយនៅពេលថ្មីៗនេះថា ការបង្រៀនខ្លឹមសារគ្រាន់តែផ្តល់ "ដំណឹងល្អមួយចំណែកប៉ុណ្ណោះ ប្រសិនបើមិនមែនជាដំណឹងល្អក្លែងក្លាយទេនោះ" (WEA Theological News, April 2008, Vol 37, No2) ។ ការបង្រៀនខ្លឹមសារគឺជាគុណវិបត្តិយ៉ាងធ្ងន់ធ្ងរ ។ ការបង្រៀនអ្នកដើរតាមឱ្យ*ស្តាប់បង្គាប់* គឺជាជំហានចុងក្រោយដ៏សំខាន់នៅក្នុងបញ្ញត្តិរបស់ព្រះយេស៊ូវដល់យើង ។ *នោះគឺជាវិធីដើម្បីឱ្យបានដល់គោលដៅ*។ ប្រសិនបើយើងមិនបង្រៀនវិធីដើម្បីឱ្យបានដល់គោលដៅទេ សិរីល្អដែលព្រះជាម្ចាស់បានបង្កើតយើងមកឱ្យឆ្លុះបញ្ចាំងនោះ នឹងថយចុះយ៉ាងខ្លាំង ។ អ្នកដែលបានប្រែចិត្តនៅក្រោមព័ន្ធកិច្ចមិនពេញលេញនេះអាចត្រូវបានសង្គ្រោះ ប៉ុន្តែពួកគេប្រថុយនឹងធ្វើឱ្យព្រះជាម្ចាស់អាប់ឱនព្រះកិត្តិយសជាជាងថ្វាយព្រះកិត្តិយសដល់ព្រះអង្គ ។

ពួកយើងភាគច្រើនដឹងអំពីការស្រាវជ្រាវដែលបង្ហាញអំពីការខុសប្លែកតិចតួចរវាងគុណតម្លៃ និងរបៀបរស់នៅរបស់អ្នកមិនជឿ និងអ្នកដែលប្រកាសថាជាគ្រីស្ទបរិស័ទ ។ ខ្ញុំគិតថា ភាពប្រែប្រួលនេះគឺជាមូលហេតុដែលបងប្អូនជនជាតិប្រេស៊ីលរបស់ខ្ញុំមិនបានមើលឃើញការផ្លាស់ប្រែនៅក្នុងសហគមន៍របស់ពួកគេដែលពួកគេបានរំពឹងទុកថានឹងកើតមាន ។ ហើយខ្ញុំសង្ស័យថា នោះគឺជាមូលហេតុដែលយើងមើលឃើញមានការរាយការណ៍អំពីចំនួនអ្នកប្រែចិត្ត និងការដាំក្រុមជំនុំបានយ៉ាងច្រើន តែមិនមានការបំផ្លាស់បំប្រែដែលយើងជឿថា ដំណឹងល្អគួរតែបង្កើតមកនោះ ។

## ត្រួវចំគោលដៅ

នៅក្នុងអត្ថបទមួយដែលនៅក្នុង *បេសកកម្មដំណឹងល្អប្រចាំត្រីមាស* (ខែតុលា ឆ្នាំ២០០៥) ខ្ញុំបានបកស្រាយថា ការបំផ្លាស់បំប្រែមិនមែនជាកិច្ចការដែលអ្នកដើរតាមព្រះគ្រីស្ទសម្រេចទេ ។ បទគម្ពីរបង្ហាញប្រាប់យ៉ាងច្បាស់ថា ការបំផ្លាស់បំប្រែស្របតាមព្រះគម្ពីរគឺជាកិច្ចការដែល*ព្រះជាម្ចាស់*សម្រេច ជាលទ្ធផលដែលប្រជារាស្ត្ររបស់ព្រះអង្គរស់នៅតាម

របៀបដែលព្រះអង្គដែលព្រះអង្គបានត្រាស់ហៅពួកគេឱ្យរស់នៅ។ ខគម្ពីរដែលអ្នកចូលរួមនៅក្នុងសកម្មភាពបំផ្លាស់បំប្រែគ្រីស្ទបរិស័ទលើកឡើងនោះសន្យាថាៈ "នោះបើរាស្ត្រអញ ដែលបានហៅតាមឈ្មោះអញ គេបន្ទាបខ្លួន ហើយអធិស្ឋានរកមុខអញ ព្រមទាំងងាកបែរចេញពីផ្លូវអាក្រក់របស់គេ នោះអញនឹងស្តាប់ពីលើស្ថានសួគ៌ ហើយនឹងអត់ទោសអំពើបាបរបស់គេ ទាំងមើលស្រុកគេឱ្យជាផង" (២ របាក្សត្រ ៧:១៤)។

ខ្ញុំបរប្រយោគខគម្ពីរនេះថា "*បើ*ប្រជារាស្ត្ររបស់អញនឹងរស់នៅតាមរបៀបដែលអញបានរៀបចំឱ្យពួកគេរស់នៅ អញនឹងបំផ្លាស់បំប្រែភាពខ្ទេចខ្ទាំរបស់ពួកគេឱ្យបានសេចក្តីសុខសាន្តរបស់អញ" ឬ "*បើ*ប្រជារាស្ត្រដែលជាពួកជំនុំរបស់អញនឹងស្តាប់បង្គាប់តាមឱវាទដែលអញបានឱ្យពួកគេ គឺប្រសិនបើពួកគេរស់នៅតាមផ្នែកចុងក្រោយនៃសេចក្តីបង្គាប់ពេលដែលអញបែកចេញពីពួកគេ អញសន្យាថានឹងបំផ្លាស់បំប្រែពួកគេ គ្រួសាររបស់ពួកគេ សហគមន៍របស់ពួកគេ និងប្រទេសជាតិរបស់ពួកគេ"។

សេចក្តីសន្យានៅក្នុខគម្ពីរនេះមានលក្ខខណ្ឌ។ សេចក្តីសន្យានេះក៏អស្ចារ្យផងដែរ។ លក្ខខណ្ឌគឺបន្ទាបខ្លួនប្រែចិត្តពីការមិនស្តាប់បង្គាប់ ហើយស្តាប់បង្គាប់វិញ។ ដំណឹងល្អសន្មត់ថា បើគ្មានព្រះគ្រីស្ទទេ យើងស្លាប់។ "ស្លាប់" គឺយើងមិនអាចប្រោសខ្លួនយើងឱ្យបានជាទេ ទោះបីជាយើងមានប្រាជ្ញា មានលុយ និងមានទ្រព្យសម្បត្តិក៏ដោយ យើងមិនអាចប្រោសភាពខ្ទេចខ្ទាំរបស់យើងឱ្យជាបានទេ។ ការប្រោសជីវិត និងសង្គមដែលខ្ទេចខ្ទាំរបស់យើងឱ្យជាគឺជាកិច្ចការដែលទាមទារឱ្យមានការអន្តរាគមន៍យ៉ាងអស្ចារ្យ។ នៅពេលដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់ស្តាប់បង្គាប់ នៅពេលដែលពួកគេរស់នៅតាមដែលព្រះអង្គបានត្រាស់ហៅពួកគេឱ្យរស់នៅ ព្រះអង្គអន្តរាគមន៍យ៉ាងអស្ចារ្យនៅក្នុងការពិតរបស់ពួកគេ ដោយប្រើប្រាជ្ញា លុយ អំណាច និងធនធានដទៃទៀតរបស់ពួកគេ ដើម្បីនាំមកនូវការប្រោសឱ្យជារបស់ព្រះអង្គ។ ប៉ុន្តែប្រសិនបើយើងមិនរស់នៅតាមរបៀបរបស់ព្រះជាម្ចាស់ទេ សេចក្តីសន្យានេះទុកជាមោឃៈ។

ជារួមមក លោកម៉ាថាយប្រែមហាបេសកកម្មថា បញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍។ ការផ្សាយដំណឹងល្អ ការដាំពួកជំនុំ និងការបង្រៀនអំពីជំនឿដ៏អស្ចារ្យរបស់យើងគឺជាសកម្មភាពដ៏សំខាន់នៅតាមផ្លូវដែលនាំទៅឯជំហានចុងក្រោយ គឺការបង្រៀនអំពីការស្តាប់បង្គាប់។ ទោះបីជាផ្នែកទាំងនេះរបស់មហាបេសកកម្មមានសារៈសំខាន់ក៏ដោយ ផ្នែកទាំងនេះមិនអនុញ្ញាតឱ្យយើងថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ដូចដែលព្រះអង្គចង់បានទេ។ ដោយប្រើការប្រៀបប្រដូចកាលពីមុន គឺធ្នូរ និងគ្រាប់ព្រួញ ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំគឺប្រៀបបីដូចជាដាក់ខ្សែធ្នូរ។ ការបង្រៀនប្រៀបបីដូចជាទាញគ្រាប់ព្រួញទៅនឹងខ្សែ។ ការតម្រង់គោលដៅ និងការព្រលែងគ្រាប់ព្រួញគឺជាជំហានចុងក្រោយ ឬជាវិធីបាញ់ចំគោលដៅ។ ប្រសិនបើមិនតម្រង់គ្រាប់ព្រួញឱ្យត្រូវទេ គ្រាប់ព្រួញនឹងហោះកាត់លំហដោយមិនចំគោលដៅ! គ្រប់ទាំងសាសន៍នឹងមិនត្រូវបានបញ្ចុះបញ្ចូលឱ្យទៅជាសិស្សសម្រាប់ជាសិរីល្អដល់ព្រះជាម្ចាស់ឡើយ រហូត

ដល់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ថ្វាយសិរីល្អដល់ព្រះអង្គ ដោយរស់នៅតាមរបៀបរបស់ព្រះអង្គ គឺធ្វើតាមសេចក្តីដែលព្រះអង្គបង្គាប់ជារៀងរាល់ថ្ងៃ ជារៀងរាល់ពេល ។

ការបំផ្លាស់បំប្រែស្របតាមព្រះគម្ពីរមិនមែនកើតឡើងភ្លាមៗទេ ក៏មិនទាំងស្រុងដែរ មុនពេលដែលនគររបស់ព្រះគ្រីស្ទតាំងឡើងជាពោរពេញនោះ ។ ប៉ុន្តែប្រវត្តិសាស្ត្របង្ហាញឱ្យយើងឃើញថា ការបំផ្លាស់បំប្រែអាចជាតថៈភាពដ៏សំខាន់នៅពេលឥឡូវនេះ ។ សង្គមវិទូ រ៉ូឌុនី ស្តាក បានពិនិត្យមើលការបំផ្លាស់បំប្រែសង្គមដ៏មិនគួរឱ្យជឿរបស់ចក្រភពរ៉ូមនៅក្នុងរយៈពេលបីរយឆ្នាំដំបូងរបស់ពួកជំនុំគ្រីស្ទបរិស័ទ (*ការងើបឡើងរបស់ជំនឿគ្រីស្ទបរិស័ទ* រោងពុម្ពសកលវិទ្យាល័យប្រ៊ីនថុន ឆ្នាំ១៩៩៦) ។ មានការបំផ្លាស់បំប្រែស្រដៀងគ្នានៅក្នុងពេលបដិវត្តន៍កំណែទម្រង់ និងការផុសផុលរបសវេស្លៀន ។ នៅក្នុងសម័យកាលនិមួយៗទាំងនេះ មានការបង្ហាញចេញពីការស្តាប់បង្គាប់យ៉ាងអស្ចារ្យ ដោយត្រូវបានគេស្គាល់តាមរយៈការបង្ហាញចេញពីសេចក្តីស្រឡាញ់ដែលហ៊ានលះបង់របស់ព្រះគ្រីស្ទ ដោយអ្នកដែលត្រូវបានហៅតាមព្រះនាមរបស់ព្រះអង្គ ។

ខ្ញុំជឿថា ការបំផ្លាស់បំប្រែតែមួយអាចកើតមាននៅពេលសព្វថ្ងៃនេះ ប៉ុន្តែភាពដែលអាចកើតមាននោះមានលក្ខខណ្ឌ ។ ព្រះជាម្ចាស់បានមានបន្ទូលប្រាប់យ៉ាងច្បាស់អំពីលក្ខខណ្ឌនៅក្នុង ២ របាក្សត្រ ៧:១៤ ។ មានលក្ខខណ្ឌពីរៈ (១) ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ត្រូវបន្ទាបខ្លួននៅចំពោះព្រះអង្គ ហើយស្វែងរកព្រះភក្ត្ររបស់ព្រះអង្គ មានន័យថា គេត្រូវចូលមកដោយប្រែចិត្តនៅចំពោះព្រះអង្គ ហើយដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះអង្គ (២) ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ត្រូវបែរចេញពីផ្លូវអាក្រក់របស់ខ្លួន មានន័យថា ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ។ នៅពេលដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់បំពេញលក្ខខណ្ឌទាំងពីរនេះ មានសេចក្តីសន្យាពីរផងដែរ ។ ដោយនៅក្នុងសិរីល្អរបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់ (១) អត់ទោស និង (២) មើលឱ្យជា ។

## តើយើងដឹងយ៉ាងដូចម្តេច ពេលដែលយើងបានបាញ់ចំគោលដៅ?

តើយើងដឹងយ៉ាងដូចម្តេច ពេលដែលយើងបានបាញ់ចំគោលដៅ? តើមើលទៅមានលក្ខណៈយ៉ាងដូចម្តេច នៅពេលដែលសិស្សម្នាក់ៗ និងនៅពេលពួកជំនុំ ថ្វាយសិរីល្អដល់ព្រះជាម្ចាស់? បទគម្ពីរជួយយើងឆ្លើយសំណួរនេះ

ចិត្តអាណិតអាសូរជួយស្ទាងអ្នកដែលខ្ទេចខ្ទាំ

*"ចូរទៅប្រាប់យ៉ូហានពីសេចក្តីទាំងប៉ុន្មានដែលអ្នកកំពុងតែឮ ហើយឃើញចុះ គឺថាមនុស្សខ្វាក់បានភ្លឺ មនុស្សខ្វិនបានដើររួច មនុស្សឃ្លង់បានជាស្អាត មនុស្សថ្លង់បានឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយមនុស្សទាល់ក្របានឮដំណឹងល្អផង"* (ម៉ាថាយ ១១:៤-៥)។

ព្រះយេស៊ូវមានបន្ទូលថា ព្រះអង្គបានយាងមកដើម្បីធ្វើតាមបំណងព្រះហឫទ័យនៃព្រះវរបិតារបស់ព្រះអង្គ (យ៉ូហាន ៦:៣៨)។ តើនោះមានន័យយ៉ាងដូចម្តេច? យើងមើលឃើញចម្លើយមួយនៅក្នុងការឆ្លើយតបរបស់ព្រះយេស៊ូវទៅកាន់ពួកសិស្សរបស់លោកយ៉ូហាននៅខាងលើនេះ។ ខ្ញុំក៏ឃើញថាមានប្រយោជន៍ផងដែរនឹងមើលចំណងជើងប្រធានបទនៅក្នុងកណ្ឌគម្ពីរម៉ាកុសក្នុងព្រះគម្ពីរ NIV របស់ខ្ញុំ។ ឧទាហរណ៍រួមមានដូចជា: "ព្រះយេស៊ូវដេញអារក្ស" "ព្រះយេស៊ូវប្រោសមនុស្សជាច្រើនឱ្យបានជា" "ព្រះយេស៊ូវប្រោសមនុស្សស្លាប់ដៃជើង" "ព្រះយេស៊ូវធ្វើឱ្យព្យុះស្ងប់" "ការប្រោសមនុស្សអារក្សចូលឱ្យជា" "ការប្រោសមនុស្សខ្វាក់ម្នាក់នៅបេតសៃដា" "មនុស្សខ្វាក់បាទីម៉េមើលឃើញ" និង "ព្រះយេស៊ូវសម្អាតព្រះវិហារ"។ មានការប្រាប់ជាប្រយោសម្រាប់យើង ដែលជាអ្នកដើរតាមព្រះយេស៊ូវ:

១. ព្រះជាម្ចាស់ហាក់បីដូចជាមានព្រះហឫទ័យអាណិតអាសូរនឹងប្រោសភាពខ្ទេចខ្ទាំឱ្យបានជា។ *សំណួរ:* តើយើងកំពុងធ្វើអ្វីដោយរៀង១ខ្លួន និងដោយរួមគ្នា ដើម្បីប្រោសភាពខ្ទេចខ្ទាំរបស់អ្នកដែលនៅជុំវិញយើងឱ្យបានជា?
២. យើងមើលឃើញភស្តុតាងអំពីភាពធំឧត្តមរបស់ព្រះជាម្ចាស់លើចក្រវាឡ។ *សំណួរ:* តើយើងយើងកំពុងធ្វើអ្វីដោយរៀង១ខ្លួន និងដោយរួមគ្នាដើម្បីឆ្លុះបញ្ចាំងពីព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះភាពខ្ទេចខ្ទាំចរបស់បរិដ្ឋានខាងសាច់ឈាមរបស់យើង?
៣. យើងមើលឃើញភស្តុតាងអំពីព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះការធ្វើឱ្យទីបរិសុទ្ធទៅជាមិនបរិសុទ្ធ។ *សំណួរ:* តើយើងកំពុងធ្វើអ្វីដោយរៀង១ខ្លួន និងដោយរួមគ្នាដើម្បីប្រោសភាពខ្ទេចខ្ទាំនៅក្នុងគ្រួសារ នៅក្នុងពួកជំនុំ និងនៅក្នុងសហគមន៍របស់យើងឱ្យបានជា?
៤. យើងមើលឃើញភស្តុតាងអំពីការអន្តរាគមន៍ដ៏អស្ចារ្យដើម្បីប្រោសភាពខ្ទេចខ្ទាំរបស់មនុស្ស និងរបស់ចក្រវាឡឱ្យបានជា។ "*កាលបានឃើញថា ពេត្រុស និងយ៉ូហានមានចិត្តក្លាហាន នោះពួកលោកទាំងនោះក៏មានសេចក្តីអស្ចារ្យ ដោយដឹងថា គេជាមនុស្សមិនសូវចេះជ្រៅជ្រះ ហើយឥតបានរៀនសូត្រប៉ុន្មានផង បានជាលោកយល់ឃើញថា គេធ្លាប់នៅជាមួយនឹងព្រះយេស៊ូវ*" (កិច្ចការ ៤:១២)។ *សំណួរ:* តើពិភពលោកដែលកំពុងតែសម្លឹងមើលភ្ញាក់ផ្អើលនឹងបានឃើញភស្តុតាងអំពីការអន្តរាគមន៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង និងនៅក្នុងការបម្រើរបស់យើងដល់អ្នកដទៃទៀតដែរឬទេ?

នៅពេលដែលយើងចាប់ផ្តើមព័ន្ធកិច្ចរបស់យើងនៅក្នុងប្រទេសហៃទី យុវជនគ្រីស្ទបរិស័ទមួយក្រុមនៅក្នុងតំបន់ក្រីក្របំផុតត្រូវបានលើកទឹកចិត្តឱ្យធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ នៅពេលដែលពួកគេបានអធិស្ឋាន ព្រះវិញ្ញាណបាននាំពួកគេឱ្យចាប់អារម្មណ៍នឹងបុរសចំណាស់ម្នាក់ដែលមានជម្ងឺកំពុងរស់នៅក្នុងខ្ទមដ៏កខ្វក់ ។ ពួកគេបានទៅខ្ទមរបស់បុរសនេះ ។ ពួកគេបានងូតទឹកឱ្យគាត់ ស្លៀកសម្លៀកបំពាក់ស្អាតឱ្យគាត់ ឱ្យអាហារគាត់បរិភោគ និងបានសម្អាតភាពកខ្វក់នៅក្នុងបន្ទប់ដ៏តូចរបស់គាត់ ។ អ្នករស់នៅក្នុងតំបន់ក្រីក្រនោះ ពេលដែលដើរកាត់ *បានភ្ញាក់ផ្អើល* និងបាននិយាយថា "អ្នកទាំងនេះប្រាកដជាគ្រីស្ទបរិស័ទហើយ!" ។

<u>ការរងទុក្ខ</u>

*" តែយើងឃើញព្រះយេស៊ូវវិញ ដែលព្រះបានធ្វើឱ្យទាបជាងពួកទេវតាបន្តិច ទ្រង់ពាក់សិរីល្អ និងល្បីព្រះនាមទុកជាមកុដ ដោយព្រោះទ្រង់បានរងទុក្ខសុគត ដើម្បីនឹងភ្លក់សេចក្តីស្លាប់ជំនួសមនុស្សទាំងអស់ ដោយនូវព្រះគុណនៃព្រះ ដ្បិតឯព្រះដែលគ្រប់របស់ទាំងអស់សំរាប់ទ្រង់ ហើយដោយសារទ្រង់ កាលទ្រង់ចង់នាំកូនជាច្រើនមកក្នុងសិរីល្អ នោះគួរគប្បីឱ្យទ្រង់បានធ្វើឱ្យមេនៃសេចក្តីសង្គ្រោះគេ បានគ្រប់លក្ខណ៏ដោយរងទុក្ខលំបាក"* (ហេព្រើរ ២:៩-១០) ។

មានវិធីមួយដែលការរងទុក្ខអាចឆ្លុះបញ្ចាំងពីសិរីល្អរបស់ព្រះជាម្ចាស់បាន ព្រះយេស៊ូវបានរងទុក្ខដោយលះបង់ មិនមែនសម្រាប់ព្រះអង្គទ្រង់ទេ ប៉ុន្តែសម្រាប់អ្នកដទៃវិញ ។ នៅពេលដែលយើងរងទុក្ខសម្រាប់អ្នកដទៃ យើងឆ្លុះបញ្ចាំងពីអ្វីដែលព្រះយេស៊ូវបានធ្វើសម្រាប់យើង ។

*សំណួរ:* នៅពេលដែលយើងមើលអ្នកដើរតាមព្រះយេស៊ូវម្នាក់ៗនៅក្នុងពួកជំនុំរបស់យើង តើយើងមើលឃើញសិរីល្អរបស់ព្រះជាម្ចាស់ នៅពេលដែលពួកគេរងទុក្ខសម្រាប់អ្នកដទៃទៀតដែរឬទេ? នៅពេលដែលអ្នកនៅក្នុងសហគមន៍របស់យើងមើលមកពួកជំនុំរបស់យើង តើពួកគេមើលឃើញអ្នកដើរតាមព្រះយេស៊ូវដែល "ឱ្យរហូតដល់ឈឺចាប់" ដើម្បីប្រោសភាពខ្ទេចខ្ទាំនៅក្នុងសហគមន៍របស់ពួកគេឱ្យបានជាដែរឬទេ?

ក្រុមកោសិកាមួយក្នុងចំណោមក្រុមកោសិកានៃពួកជំនុំមួយនៅអាហ្វ្រិកបានមើលឃើញសេចក្តីត្រូវការរបស់ក្មេងជនជាតិអ៊ីស្លាមនៅក្នុងសហគមន៍របស់ពួកគេដែលត្រូវការម្ហូបអាហារ សម្លៀកបំពាក់ និងសាលារៀន ។ ពួកគេបានលះបង់ធនធានបន្តិចបន្តួចរបស់ពួកគេដើម្បីងូតទឹកឱ្យ ផ្តល់ម្ហូបអាហារ និងបង្រៀនក្មេងនៅក្នុងផ្ទះរបស់ពួកគេផ្ទាល់ ។ ឪពុកម្តាយដែលមានមន្ទិលសង្ស័យពីដំបូងនោះ បានប៉ះពាល់ចិត្ត នៅពេលដែលពួកគេបានមើលឃើញការបង្ហាញចេញពីសិរី

ល្អរបស់ព្រះជាម្ចាស់តាមបែបនេះ។ អ្នកជិតខាងមួយចំនួនឥឡូវនេះកំពុងតែក្លាយទៅជាមនុស្សដែលឆ្លុះបញ្ចាំងពីសិរីល្អតែមួយដែលបានធ្វើឱ្យពួកគេភ្ញាក់ផ្អើលនោះ។

<u>ស្រឡាញ់គ្នាទៅវិញទៅមក</u>

*"ពួកអ្នកដែលជឿទាំងប៉ុន្មានក៏នៅជាមួយគ្នា ហើយមានរបស់ទាំងអស់នៅមូលព្រមគ្នា គេក៏លក់ទ្រព្យសម្បត្តិ និងរបស់គេទាំងប៉ុន្មានចែកដល់គ្នា តាមដែលគ្រប់គ្នាត្រូវការ រាល់តែថ្ងៃ គេនៅតែព្យាយាមក្នុងព្រះវិហារ ដោយមានចិត្តព្រមព្រៀងគ្នា ឯកាលនៅផ្ទះ ក៏កាច់នំបុ័ង ហើយបរិភោគអាហារដោយអំណរ និងចិត្តស្មោះត្រង់ ព្រមទាំងសរសើរដល់ព្រះ ហើយបណ្តាជនទាំងអស់គ្នាក៏រាប់អានគេ ចំណែកព្រះអម្ចាស់ទ្រង់ក៏បន្ថែមនូវអស់អ្នកដែលកំពុងតែបានសង្គ្រោះរាល់តែថ្ងៃទៅក្នុងពួកជំនុំថែមទៀត"* (កិច្ចការ ២:៤៤-៤៧)។

ភស្តុតាងមួយផ្សេងទៀតអំពីសិរីល្អរបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញឱ្យឃើញតាមរយៈការមើលថែដោយសេចក្តីស្រឡាញ់ដែលពួកអ្នកជឿដំបូងមានចំពោះគ្នាទៅវិញទៅមក។

*សំណួរ:* តើមនុស្សនៅក្នុងសហគមន៍របស់យើងមើលឃើញអ្វី និងឮអ្វីតាមរយៈការមើលថែគ្នាទៅវិញទៅមករបស់យើង?

<u>ចិត្តសប្បុរសចំពោះអ្នកដែលយើងមិនស្គាល់</u>

*"កាលមានសេចក្តីទុក្ខលំបាកកំពុងតែល្បងគេជាខ្លាំង នោះសេចក្តីអំណរជាបរិបូរ និងសេចក្តីកំសត់ទុរគតរបស់គេ បានបណ្តាលឱ្យគេមានចិត្តសទ្ធាដ៏លើសលប់វិញ ដ្បិតខ្ញុំធ្វើបន្ទាល់ថា គេស្ម័គ្រចិត្តតាមកំឡាំងគេ ហើយហួសកំឡាំងគេផង"* (២ កូរិនថូស ៨:២-៣)។

បទគម្ពីរអបអរនឹងការឆ្លុះបញ្ចាំងពីសិរីល្អរបស់ព្រះជាម្ចាស់តាមបែបនេះ។ ឧទាហរណ៍ នៅក្នុង ២ កូរិនថូស ៨:១-១៥ ប៉ុលសរសើរអ្នកស្រុកម៉ាសេដូនដែលបានថ្វាយលើសពីសមត្ថភាពរបស់ពួកគេសម្រាប់អ្នកជឿដែលខ្វះខាតនៅក្នុងក្រុងយេរូសាឡិម គឺជាអ្នកជឿដែលពួកគេមិនដែលបានជួបទេ។

បីឆ្នាំមុន នៅក្នុងប្រទេសរបស់ខ្ញុំ យើងបានជួបគ្រោះធម្មជាតិដ៏ធំបំផុតមួយនៅក្នុងប្រវត្តិសាស្ត្ររបស់យើង គឺព្យុះកំពុតត្បូង ខេតទ្រីណា ហើយគឺជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដែលបានឆ្លើយតបភ្លាមៗ ដោយសេចក្តីស្រឡាញ់ ជំនួយចិត្តអាណិតអាសូរ និងកំឡាំងមនុស្សសម្រាប់សម្អាត និងស្ថាបនាឡើងវិញ លើសជាងរដ្ឋាភិបាលរបស់យើងដែលមាន

លុយរាប់កោដិដុល្លា (Heralding Unheard Voices, Homeland Security Institute, US Government, December 2006) ។ បីឆ្នាំក្រោយមក ពួកជំនុំជាច្រើននៅតែបន្តការចូលរួមរបស់ពួកគេ ។

ផ្នែកបន្ថែមនៃការបម្រើនេះគឺជាសេចក្តីចៅរ៉ៅ ដែលជាលក្ខណៈមួយត្រូវបានរំពឹងទុកពីអស់អ្នកដែលត្រូវបានហៅឈ្មោះតាមព្រះគ្រីស្ទ ។ សូមមើល រ៉ូម ១២:១៣, ១ ធីម៉ូថេ ៣:២ និង ៥:១០ ទីតុស ១:៨ និង ១ពេត្រុស ៤:៩ ។

*សំណួរ:* តើមនុស្សដែលយើងមិនដែលបានជួបមើលឃើញសិរីល្អរបស់ព្រះជាម្ចាស់តាមរយៈសេចក្តីសប្បុរសរបស់យើងដែរឬទេ? តើមនុស្សនៅក្នុងសហគមន៍របស់យើងបានប៉ះពាល់ចិត្តដោយសារសិរីល្អរបស់ព្រះជាម្ចាស់តាមរយៈសេចក្តីចៅរ៉ៅរបស់យើងដែរឬទេ?

<u>សហគមន៍ដែលបានបំផ្លាស់បំប្រែ</u>

*"ចូរហាត់រៀនធ្វើការល្អវិញ ចូរស្វែងរកឱ្យបានសេចក្តីយុត្តិធម៌ ចូរជួយការពារចំពោះមនុស្សដែលត្រូវគេសង្កត់សង្កិន ចូរកាត់ក្តីដល់ពួកកំព្រា ហើយកាន់ក្តីជំនួសពួកស្រីមេម៉ាយចុះ"* (អេសាយ ១:១៧) ។

ប្រសិនបើព្រះយេស៊ូវគឺជាចៅហ្វាយក្រុង...ប្រសិនបើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅក្នុងគ្រួសារ និងសហគមន៍របស់យើង...ប្រសិនបើមិនមានអំពើពុករលួយនៅក្នុងរដ្ឋាភិបាល...ប្រសិនបើពាណិជ្ជកម្មមានភាពស្មោះត្រង់...ប្រសិនបើមានសន្តិភាពរវាងវណ្ណៈផ្សេងៗ និងជនជាតិផ្សេងៗ...ប្រសិនបើអ្នកទាបថោកត្រូវប្រព្រឹត្តដាក់ដោយសេចក្តីថ្លៃថ្នូរ និងយុត្តិធម៌...សេចក្តីណាមួយក្នុងចំណោមសេចក្តីទាំងនេះ ឬសេចក្តីទាំងអស់នេះគឺជាអ្វីដែលយើងនឹងរំពឹងថានឹងមើលឃើញ ប្រសិនបើយើងកំពុងតែធ្វើជាសិរីល្អរបស់ព្រះជាម្ចាស់ ។

ប៉ុន្តែ ទាំងនេះមិនមែនជាគោលដៅដែលយើងអាចសម្រេចបានដោយកំឡាំងខាងសាច់ឈាមរបស់យើងទេ ទាំងនេះគឺជាលទ្ធផលនៃការអន្តរាគមន៍ដ៏អស្ចារ្យនៅក្នុងពិភពលោកដែលខ្ទេចខ្ទាំរបស់យើង ។ យើងនឹងមើលឃើញសេចក្តីទាំងនេះ...ប្រសិនបើ ។ *ប្រសិនបើ* គឺអាស្រ័យលើយើងបំពេញលក្ខខណ្ឌដែលព្រះជាម្ចាស់បានដាក់ គឺបន្ទាបខ្លួនស្តាប់បង្គាប់ព្រះអង្គ ។

យើងចង់មើលឃើញសេចក្តី "ប្រសិនបើ" ខាងលើនេះក្លាយទៅជាការពិត ប៉ុន្តែសេចក្តីទាំងនេះគឺជាលទ្ធផលនៃការរស់នៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ ប្រសិនបើយើងខំប្រឹងធ្វើការឆ្ពោះទៅរកលទ្ធផលទាំងនេះជាគោលដៅរបស់យើង ដោយមិនបង្រៀនប្រជារាស្ត្ររបស់ព្រះជាម្ចាស់ឱ្យ*រស់នៅ*តាមដំណឹងល្អនៅក្នុងជីវិតប្រចាំថ្ងៃ និងនៅក្នុងពិភពលោករបស់ពួកគេទេ សហគមន៍របស់យើងនឹងមិនត្រូវបានបំផ្លាស់បំប្រែឡើយ ។ រូបកាយរបស់ព្រះគ្រីស្ទគួរតែចូលរួមទាំងនៅក្នុងការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនពីសិរីល្អរបស់ព្រះជាម្ចាស់ និងទាំងនៅក្នុងការខិតខំប្រឹងប្រែងរួមគ្នាដើម្បីពង្រីក

សេចក្ដីយុត្តិធម៌ និងសេចក្ដីមេត្តាករុណា។ ប៉ុន្តែការខិតខំប្រឹងប្រែង និងកម្មវិធីផ្សេងៗរួមគ្នានឹងមិនបង្កើតឱ្យមានការផ្លាស់ប្រែឡើយ ប្រសិនបើអ្នកដើរតាមព្រះយេស៊ូវម្នាក់ៗរស់នៅមិនស្ដាប់បង្គាប់តាមដែលព្រះអង្គបង្រៀនទេនោះ។

*សំណួរ:* តើយើងជឿថា ការបំផ្លាស់បំប្រែពឹងផ្អែកលើការស្ដាប់បង្គាប់ដែរឬទេ?

## តើយើងធ្វើឱ្យពួកគេបានគ្រប់លក្ខណ៍យ៉ាងដូចម្ដេច?

ប្រសិនបើកិច្ចការចុងក្រោយរបស់មហាបេសកកម្ម ដែលជាវិធីសម្រាប់ថ្វាយសិរីល្អដល់ព្រះជាម្ចាស់ គឺធ្វើឱ្យពួកសិស្សបានគ្រប់លក្ខណ៍ដើម្បី*ដឹង និងធ្វើតាម*បំណងព្រះហឫទ័យរបស់ព្រះវរបិតា សំណួរបន្ទាប់មកទៀតគឺថា "តើយើងធ្វើឱ្យពួកគេបានគ្រប់លក្ខណ៍យ៉ាងដូចម្ដេច?"។

ប្រហែលជាមានកម្មវិធី និងយុទ្ធសាស្ត្របង្កើតសិស្សច្រើនដូចជានិកាយ និងអង្គការក្រៅពួកជំនុំដែរ។ កម្មវិធីទាំងនេះជាញឹកញាប់មានគោលដៅបែបនេះ:

១. ភាពបរិសុទ្ធផ្ទាល់ខ្លួន: ទំនាក់ទំនងរវាងសិស្សជាមួយនិងព្រះជាម្ចាស់

២. ចំណេះដឹងបទគម្ពីរ

៣. បណ្ដុះបណ្ដាលសិស្សឱ្យផ្សាយដំណឹងល្អ និង/ឬដាំពួកជំនុំ

និមួយនេះគឺជាជំហានដែលចាំបាច់នៅក្នុងការបង្កើតសិស្ស ប៉ុន្តែទាំងនោះមិនមែនជាគោលដៅពេញលេញនៅក្នុងព្រះគម្ពីរទេ។ ការសង្កត់ធ្ងន់ទាំងនេះមិនអាចបាញ់ចំគោលដៅទេ។ គោលដៅអាចសម្រេចបាន តែនៅពេលណាដែលយើងធ្វើឱ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានគ្រប់លក្ខណ៍ដើម្បី *ធ្វើតាម*សេចក្ដីដែលព្រះយេស៊ូវបានបង្គាប់។

គ្រូគង្វាលមួយចំនួនចំណាយកំឡាំងយ៉ាងច្រើន ដោយលើកទឹកចិត្តឱ្យសមាជិករបស់ពួកគេឱ្យក្លាយទៅជាអ្នកធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែពួកគេមិនមើលឃើញលទ្ធផល។ ហេតុអ្វី? មានហេតុផលជាច្រើន។ ហេតុផលមួយដែលខ្ញុំឮជាញឹកញាប់គឺថា មនុស្សដែលកំពុងត្រូវបានបង្កើតឱ្យទៅជាសិស្សមិនចង់ធ្វើតាមអ្វីដែលព្រះគ្រីស្ទប្រាប់។ នោះប្រហែលជាពិតខ្លះ ប៉ុន្តែខ្ញុំគិតថា អ្វីដែលត្រូវបានចាត់ទុកថាជាការមិនព្រមធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺជា (១) ការភ័យខ្លាចន័យរបស់ការស្ដាប់បង្គាប់ (២) ខ្វះខាតចំណេះដឹងជាក់ស្ដែងអំពីរបៀបអនុវត្តនៅក្នុងបរិបទរបស់អ្នកជឿម្នាក់ៗ និង (៣) អវត្តមាននៃយុទ្ធសាស្ត្រសម្រាប់ការអនុវត្តន៍ច្បាស់លាស់ និងអាចប្រតិបត្តិបាន។ ប្រសិនបើអ្នកជឿពិតជាប្រកាសថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់មែន ខ្ញុំជឿថា មានមនុស្សជាច្រើននឹងចូលរួមស្រែកជាមួយលោកប៉ុលថា "វេទនាណាស់ខ្ញុំ..." (រ៉ូម ៧:២៤)។ ចេញពីជម្រៅចិត្តរបស់លោកមក លោកប៉ុលចង់ស្ដាប់បង្គាប់។

មានហេតុផលមួយផ្សេងទៀត ដែលយើងមិនមើលឃើញគ្រីស្ទបរិស័ទរស់នៅដោយស្តាប់បង្គាប់តាមសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ គឺទស្សនៈដែលតាមរយៈនោះយើងបង្រៀនបទគម្ពីរ ជាញឹកញាប់បានទទួលរងឥទ្ធិពលពីការកុហករបស់វប្បធម៌យើង។ នៅក្នុងវប្បធម៌របស់ខ្ញុំ ការនេះត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈឥទ្ធិពលមិនស្របតាមព្រះគម្ពីររបស់លោកិយនិយម សំភារៈនិយម និងសាបេក្ខនិយម។ ការកុហកទាំងនេះនៅក្នុងវប្បធម៌ជាញឹកញាប់បង្កប់នៅក្នុងគំនិតសន្មត់ ហើយយើងមិនដឹងអំពីការកុហកទាំងនោះទេ។ យើងត្រូវអនុវត្តវិន័យស្គាល់ការកុហក ហើយជួយសមាជិករបស់យើងឱ្យញែកការកុហកចេញពីសេចក្តីពិត។

## គោលការណ៍ប្រាំពីរ

ប្រសិនបើសិរីល្អរបស់ព្រះជាម្ចាស់គឺជាគោលដៅ ហើយប្រសិនបើការធ្វើឱ្យសមាជិករបស់យើងបានគ្រប់លក្ខណ៍សម្រាប់កិច្ចការបម្រើគឺជាមធ្យោបាយដ៏សំខាន់ឆ្ពោះទៅចុងបញ្ចប់នោះ ការបាញ់ចំគោលដៅអាចធ្វើបាន។ យ៉ាងដូចម្តេច? មានសេណារីយ៉ូអំពីការបង្កើតសិស្សជាច្រើនដែលមានប្រសិទ្ធភាព។ គោលបំណងរបស់មេរៀននេះមិនមែនផ្តល់ជូននូវយុទ្ធសាស្ត្រទេ។ ខ្ញុំជឿថា មានអ្វីមួយដែលសំខាន់ជាងយុទ្ធសាស្ត្រល្អទៅទៀត។ នោះគឺជាការចាប់យកគោលការណ៍ដែលយុទ្ធសាស្ត្រត្រូវបានសង់ឡើងនៅលើនោះ។ ខណៈពេលដែលយុទ្ធសាស្ត្រត្រូវធ្វើបរិបទុបនីយកម្មនោះ គោលការណ៍នៅក្នុងព្រះគម្ពីរមិនអាចកែប្រែ ហើយសំខាន់សម្រាប់គ្រប់យុទ្ធសាស្ត្រដែលប្រើ។ គោលការណ៍ទាំងនេះអាចត្រូវបានប្រាប់តាមរបៀបផ្សេងៗគ្នា ប៉ុន្តែខ្ញុំនឹងចែកចាយគោលការណ៍ទាំងនោះដែលហាក់បីដូចជាជោគជ័យនៅគ្រប់វប្បធម៌ និងគ្រប់សម័យកាល នៅពេលដែលយកមកអនុវត្ត។ ខ្ញុំនឹងផ្តល់ជូនគោលការណ៍ប្រាំពីរៈ

<u>គោលការណ៍ទី ១: ការពឹងអាងលើព្រះគុណដែលជួយឱ្យអាចធ្វើបាន</u>

*"បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្តីនោះនឹងបានសំរេចដល់អ្នករាល់គ្នាជាមិនខាន ព្រះវរបិតាខ្ញុំបានដំកើងឡើងដោយសេចក្តីនេះឯង គឺដោយអ្នករាល់គ្នាបង្កើតផលជាច្រើនយ៉ាង នោះអ្នករាល់គ្នានឹងធ្វើជាសិស្សខ្ញុំមែន... បើអ្នករាល់គ្នាកាន់តាមបញ្ញត្តិខ្ញុំ នោះនឹងនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ ដូចជាខ្ញុំបានកាន់តាមបញ្ញត្តិនៃព្រះវរបិតាខ្ញុំ ហើយក៏នៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ដែរ ខ្ញុំបាននិយាយសេចក្តីទាំងនេះប្រាប់ដល់អ្នករាល់គ្នា ដើម្បីឱ្យសេចក្តីអំណររបស់ខ្ញុំបាននៅជាប់ក្នុងអ្នករាល់គ្នា ហើយឱ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញផង នេះជាសេចក្តីបញ្ញត្តិរបស់ខ្ញុំ គឺឱ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"* (យ៉ូហាន ១៥:៧-៨, ១០-១២)

គោលការណ៍ទីមួយគឺជាការជួយ ឬការណែនាំសិស្សឱ្យរកឃើញ និងរក្សាទំនាក់ទំនងរបស់ពួកគេជាមួយព្រះយេស៊ូវ ប្រសិនបើសិស្សមិននៅជាប់នឹងព្រះគ្រីស្ទទេ គោលការណ៍ដទៃទៀតសម្រាប់ធ្វើឱ្យគ្រប់លក្ខណ៍នឹងមិនបង្កើតសិស្សដែលថ្វាយសិរីល្អដល់ព្រះជាម្ចាស់ឡើយ សិស្សក៏នឹងមិនក្លាយជាសិរីល្អរបស់ព្រះអង្គដែរ ។ ការខិតខំប្រឹងប្រែងរបស់ពួកគេនឹងពឹងអាងលើកម្លាំងមនុស្ស ។ ពួកគេប្រហែលជាមើលទៅល្អសម្រាប់អ្នកសំឡឹងមើលដែលនៅខាងក្រៅ ប៉ុន្តែ"ការបម្រើ" របស់ពួកគេនឹងមិនមានឥទ្ធិពលរយៈពេលខ្លី និង/ឬអស់កល្បជានិច្ចទេ ។

សិស្សមិនត្រឹមតែត្រូវមានទំនាក់ទំនងរឹងមាំជាមួយព្រះអម្ចាស់របស់ពួកគេប៉ុណ្ណោះទេ ពួកគេថែមទាំងត្រូវរៀនអំពីការពឹងអាងជាដរាបលើព្រះគុណដែលជួយឱ្យអាចធ្វើបានថែមទៀតផង គឺជាអំណាចដ៏អស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធដើម្បីធ្វើអ្វីដែលពួកគេមិនអាចធ្វើបានតាមកំឡាំងរបស់ពួកគេ ។ ការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតាជាដរាបដោយពឹងអាងលើកំឡាំងរបស់ខ្លួន មិនអាចធ្វើទៅបានឡើយ ។ ប៉ុន្តែ "*អរព្រះគុណដល់ព្រះអង្គ គឺដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា...*" (រ៉ូម ៧:២៥) ការស្តាប់បង្គាប់អាចធ្វើបាន ។ ដោយសារការស្តាប់បង្គាប់ជាដរាប ការបម្រើប្តូរពីកាតព្វកិច្ចទៅជាអំណរ ពីការកាន់តាមក្រឹត្យវិន័យទៅជាសេរីភាព ពីសាសនាទៅជាព្រះគុណ ។

<u>គោលការណ៍ទី ២: សេចក្តីសុចរិត និងកាធ្វើជាគំរូ</u>

"*ដូច្នេះ អ្នកណាដែលនឹងរំលងបទណាមួយ សូម្បីយ៉ាងតូចបំផុតក្នុងបញ្ញត្តិយទាំងនេះ ហើយបង្រៀនមនុស្សឱ្យធ្វើដូច្នោះដែរ នោះនឹងត្រូវហៅជាអ្នកតូចបំផុតក្នុងនគរស្ថានសួគ៌ តែអ្នកណាដែលកាន់តាម ហើយបង្រៀនចំពោះបញ្ញត្តទាំងនេះ នោះនឹងបានហៅជាអ្នកធំក្នុងនគរស្ថានសួគ៌វិញ*" (ម៉ាថាយ ៥:១៩) ។

ផ្នែកដ៏សំខាន់បំផុតទីពីរនៅក្នុងការបណ្តុះបណ្តាលគឺជាសេចក្តីសុចរិតរវាងអ្នកនាំព្រះរាជសារ និងព្រះរាជសារ អ្នកបង្កើតសិស្ស និងសិស្ស ។ អ្នកបណ្តុះបណ្តាលត្រូវតែធ្វើជាគំរូ ។ ព្រះយេស៊ូវបានបង្ហាញ និងបានបង្រៀនថា *ការធ្វើ* មកមុន *ការបង្រៀន*។ និយាយបានម្យ៉ាងទៀតគឺថា អ្នកបណ្តុះបណ្តាលត្រូវអភិវឌ្ឍ ឌី អិន អេ ខាងវិញ្ញាណ គឺភាពជាអ្នកបម្រើដោយហ៊ានលះបង់នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេជាមុនសិន មុនពេលដែលពួកគេលើកទឹកចិត្តសិស្សរបស់ពួកគេ ឬកូនខាងវិញ្ញាណរបស់ពួកគេឱ្យអភិវឌ្ឍ និងធ្វើដូចគ្នានោះ ។

នៅពេលដែលខ្ញុំកំពុងសរសេរមេរៀនអំពីការបង្កើតសិស្សសម្រាប់ថ្នាក់បណ្ឌិតរបស់ខ្ញុំនៅដើមឆ្នាំ ១៩៩០ ព្រះវិញ្ញាណបរិសុទ្ធបានបញ្ជាក់ឱ្យខ្ញុំដឹងថា មេរៀនអំពីការបង្កើតសិស្សដែលខ្ញុំកំពុងសរសេរនឹងគ្មានអំណាចឡើយ ប្រសិនបើខ្ញុំមិនបានសរសេរចេញពីបទពិសោធន៍ផ្ទាល់ខ្លួនទេ ។ ដូច្នេះហើយ នោះគឺជាឆ្នាំដែលខ្ញុំបានចាប់ផ្តើមស្វែងយល់អំពីវិន័យខាងវិញ្ញាណនៃការស្រឡាញ់អ្នកដទៃទៀតដោយហ៊ានលះបង់ ។ ឆ្នាំនោះបានសូនជីវិតខ្ញុំទៅថ្ងៃខាងមុខ ។

ឧទាហរណ៍ ខ្ញុំចាប់ផ្ដើមវិន័យតូចមួយដែលខ្ញុំធ្វើជាទៀងទាត់ មុនពេលដែលខ្ញុំចាកចេញពីផ្ទះទៅធ្វើការ ។ ខ្ញុំដាក់ថង់ប្លាស្ទិកមួយ ពេលខ្លះពីរ នៅក្នុងហោប៉ៅក្រោយរបស់ខ្ញុំ ។ នៅពេលដែលខ្ញុំដើរពីរប្លុកអគារទៅមកពីកន្លែងខ្ញុំចតឡានទៅការិយាល័យ ខ្ញុំរើសសម្រាម ហើយនិយាយដោយមិនដឹងខ្លួនថា "នេះគឺជាពិភពលោករបស់ព្រះវរបិតាខ្ញុំ"។ ខ្ញុំមិននិយាយអំពីការនោះ និងមិនធ្វើការនោះដើម្បីឱ្យគេឃើញដែរ ។ តាមពិតទៅ ខ្ញុំខ្មាស់នឹងអាកប្បកិរិយាមើលទៅចម្លែកនេះណាស់ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំធ្វើការនោះ។ ទោះបីជាគេបានឃើញ ឬមិនបានឃើញការបង្ហាញចេញការបម្រើបែបនេះ ឬបែបដទៃទៀតរបស់ខ្ញុំក៏ដោយ បទពិសោធន៍ទាំងនោះអនុញ្ញាតឱ្យខ្ញុំបង្រៀន និងណែនាំអ្នកដទៃទៀតអំពីការបង្ហាញចេញសេចក្ដីស្រឡាញ់របស់ព្រះវរបិតានៃយើងតាមរបៀបតូច និងរបៀបធំ ។

<u>គោលការណ៍ទី ៣: ការបន្តបង្រៀន</u>

*"ឯអាហាររឹង នោះសំរាប់តែមនុស្សធំដែលបានបង្ហាត់ឥន្ទ្រីដោយធ្លាប់ខ្លួនហើយដើម្បីឱ្យបានដឹងខុសត្រូវ"* (ហេព្រើរ ៥:១៤) ។

*"ខ្ញុំបានបង្ហាញអ្នករាល់គ្នា ដោយគ្រប់ការទាំងអស់ថា គួរឱ្យខំធ្វើការដូច្នោះ ដើម្បីឱ្យបានជួយដល់ពួកអ្នកខ្សោយ ហើយនិងនឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូវ ដែលទ្រង់មានបន្ទូលថា "ដែលឱ្យ នោះបានពរជាជាងទទួល"* (កិច្ចការ ២០:៣៥) ។

គោលការណ៍ទីបីគឺបន្តបង្រៀន គឺបន្តពង្រឹង និងណែនាំអំពីភាពចាំបាច់នៃអ្វីដែលអាចត្រូវបានហៅថា វិន័យជំនឿ ។ តើវិន័យជំនឿគឺជាអ្វី? នោះគឺជារបៀបរស់នៅដោយមានវិន័យ និងមានបំណងអនុញ្ញាតឱ្យវិញ្ញាណនៃភាពជាអ្នកបម្រើដែលហ៊ានលះបង់របស់ព្រះគ្រីស្ទហូរកាត់គ្រប់ទាំងគំនិត ពាក្យសំដី និងការប្រព្រឹត្តិរបស់យើង។ គោលការណ៍នេះអាចត្រូវបានណែនាំឱ្យស្គាល់តាមរយៈការបង្រៀនជាបន្តបន្ទាប់។ ទោះបីយ៉ាងណាក៏ដោយ វិន័យជំនឿមិនអាចនៅជានិរន្តនៅក្នុងក្រុមជំនុំមូលដ្ឋានបានទេ ប្រសិនបើគោលការណ៍នោះមិនបានជ្រាបចូលទៅក្នុងការបង្រៀន ការបង្កើតសិស្ស និងការណែនាំសមាជិកទេនោះ។ ប្រសិនបើការបង្រៀន និងកាធ្វើជាគំរូអំពីភាពជាអ្នកបម្រើដែលហ៊ានលះបង់មើលមិនឃើញច្បាស់លាស់ទេ នោះត្រូវតែមានបំណងឱ្យគេយល់ដោយប្រយោលនៅក្នុងដំណើរការ បណ្ដុះបណ្ដាលទាំងមូលដើម្បីមានឥទ្ធិពលជាអតិបរិមាលើរបៀបរស់នៅបម្រើព័ន្ធកិច្ចរបស់ក្រុមជំនុំមូលដ្ឋាន។ ហេតុអ្វី? ការរស់នៅក្នុងជំនឿរបស់យើងតាមរបៀបមួយដែលឆ្លុះបញ្ចាំងឱ្យឃើញសេចក្ដីដែលព្រះយេស៊ូវបានធ្វើជាគំរូ និងបានបង្រៀន គឺភាពជាអ្នកបម្រើដែលហ៊ានលះបង់ គឺជាយន្តការដ៏សំខាន់សម្រាប់ឱ្យទៅដល់គោលដៅ គឺការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ <u>*និង*</u> ធ្វើជាសិរីល្អរបស់ព្រះអង្គ។ នៅក្នុងភីលីព ២:៥ លោកប៉ុលរំលឹកយើងថា យើងត្រូវមានឥរិយាបថតែមួយដែលព្រះ

យេស៊ូវមាន គឺតវិយាបថជាអ្នកបម្រើ។ លោកអេសាយឆ្លុះបញ្ចាំងចំណុចតែមួយនេះនៅក្នុងអេសាយ ៤៩:៥ នៅពេលដែលលោកបានទទួលស្គាល់ថា ការធ្វើជាអ្នកបម្រើរបស់ព្រះជាម្ចាស់គឺជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់លោក ចាប់តាំងពីពេលដែលលោកចាប់ទុំផ្ទៃម្ដាយមកម្ល៉េះ។

មានពួកជំនុំធំមួយនៅអាហ្វ្រិកខាងកើតដែលដាក់បញ្ចូលការបង្រៀន និងការប្រព្រឹត្តិបែបនេះនៅក្នុងពួកជំនុំ។ ប្រធានបទដែលត្រូវបានលើកឡើងនៅក្នុងសេចក្ដីអធិប្បាយ ថ្នាក់សិក្សាព្រះគម្ពីរ និងក្រុមកោសិកាតែងតែរំលឹកដល់សមាជិកថា ការត្រាស់ហៅដ៏ចម្បងរបស់ព្រះជាម្ចាស់គឺឱ្យរស់នៅតាមរបៀបនគររបស់ព្រះអង្គ ទាំងរៀង១ខ្លួន និងរួមគ្នា។ ការហៅឱ្យវិន័យជំនឿមើលឃើញច្បាស់ ឬមានចេតនាឱ្យយល់ដោយប្រយោលនៅក្នុងដំណើរការបណ្ដុះបណ្ដាលរបស់ពួកជំនុំនេះ។ ជាលទ្ធផល ពួកជំនុំត្រូវបានគេស្គាល់ចាប់តាំងពីសហគមន៍ដែលសមាជិករបស់ពួកគេ រស់នៅរហូតដល់ក្រសួងរដ្ឋាភិបាលថាជាពួកជំនុំដែលហ៊ានលះបង់វិនិយោគដើម្បីមើលឃើញសង្គមរបស់ពួកគេត្រូវបានប្រោសឱ្យជាពីភាពខ្ទេចខ្ទាំ។

<u>គោលការណ៍ទី ៤: ការអនុវត្តន៍</u> **<u>(សូមមើលទំព័រចុងក្រោយ)</u>

*"ពួកកូនតូចៗអើយ យើងមិនត្រូវស្រឡាញ់ដោយពាក្យសំដី ឬដោយបបូរមាត់ប៉ុណ្ណោះឡើយ គឺដោយការប្រព្រឹត្តិ និងសេចក្ដីពិតវិញ គឺយ៉ាងនោះឯងដែលយើងនឹងដឹងថា យើងកើតមកពីសេចក្ដីពិត ហើយយើងនឹងបានកំឡាចិត្តនៅចំពោះទ្រង់ផង"* (១យ៉ូហាន ៣:១៨-១៩)។

គោលការណ៍ទីបួនគឺជាការអនុវត្តន៍។ នៅកន្លែងណាដែលអាចធ្វើទៅបាន ការបង្កើតសិស្សត្រូវតែនាំទៅរកសកម្មភាពនៅពេលបច្ចុប្បន្ន មិនមែននៅពេលអនាគតទេ។ ការស្ដាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះជាម្ចាស់ត្រូវតែធ្វើនៅពេលឥឡូវនេះ។ ការធ្វើតាមនៅពេលក្រោយមិនមែនជាគំនិតល្អទេ។

គួរឱ្យសោកស្ដាយ ពេលខ្លះអ្នកបង្កើតសិស្សចាត់ទុកការអនុវត្តន៍ជាកិច្ចការសម្រាប់សិស្សដែលពេញវ័យ។ ព្រះយេស៊ូវបានប្រាប់អ្នកមានវ័យក្មេងឱ្យស្ដាប់បង្គាប់ជាមុនសិន បន្ទាប់មកដើរតាមព្រះយេស៊ូវ។ ខ្ញុំឆ្ងល់ថា លទ្ធផលនៃការផ្សាយដំណឹងល្អ និងការបង្កើតសិស្សនឹងផ្លាស់ប្ដូរយ៉ាងដូចម្ដេចទៅវិញ ប្រសិនបើយើងសូមឱ្យអ្នកស្វែងរកធ្វើអ្វីដែលព្រះយេស៊ូវបង្គាប់ជាសញ្ញាបង្ហាញថា ពួកគេចង់ដើរតាមព្រះអង្គ?

ការណែនាំអំពីដំណើរការអនុវត្តមិនមែនងាយស្រួលទេ ជាពិសេសសម្រាប់អ្នកដែលមិនបានអភិវឌ្ឍជំនាញដែលត្រូវការ។ ការដឹកនាំគ្រីស្ទបរិស័ទមួយក្រុមទៅរកការអនុវត្តន៍ប្រៀបបីដូចជាការរៀនបើកឡាន។ មុនដំបូង មានលោត

និងរលត់។ មួយរយៈពេលក្រោយមក អ្នកបើកបរដែលកំពុងតែពេញវ័យអាចសម្របសម្រួលការបញ្ជោះម៉ាស៊ីន ការកាច់ចង្កូត និងឈប់ដោយព្រះគុណ គឺដោយមិនបាច់គិត។

ប្រសិនបើពួកគេមិនបានអនុវត្តអ្វីដែលពួកគេបានរៀនទេ នឹងមានការផ្លាស់ប្តូរតិចតួចណាស់នៅក្នុងជីវិតសមាជិកពួកជំនុំ និងមនុស្សដែលនៅក្នុងពិភពរបស់ពួកគេ គឺមនុស្សដែលពួកគេត្រូវបានត្រាស់ហៅឱ្យបម្រើ។ ការដឹកនាំ ឬការសម្របសម្រួលការអនុវត្តន៍មេរៀនតម្រូវឱ្យមានជំនាញ ការបន្ទាបខ្លួន ភាពអត់ធ្មត់ ភាពខ្ជាប់ខ្ជួន សេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះព្រះយេស៊ូវ និងការប្តេជ្ញាចិត្តស្តាប់បង្គាប់តាម ដោយបង្រៀនអ្នកដទៃទៀតឱ្យស្តាប់បង្គាប់ដែរ។ ក្រៅពីការផ្សាយដំណឹងល្អ និងការបង្កើតសិស្សខាងវិញ្ញាណ ជំនាញដឹកនាំសិស្សឱ្យរស់នៅតាមរបៀប "ធ្វើ" តាមអ្វីដែលព្រះយេស៊ូវបានបង្គាប់ជាញឹកញាប់មិនត្រូវបានធ្វើជាគំរូ ឬបង្រៀននៅក្នុងសាលាព្រះគម្ពីរ ឬការបណ្តុះបណ្តាលគ្រូនៅក្នុងពួកជំនុំទេ។ ដូចជាការបើកឡានអញ្ចឹងដែរ ជំនាញនេះរៀនបានល្អបំផុតតាមរយៈបទពិសោធន៍ ប៉ុន្តែនេះគឺជាគ្រាប់ព្រួញមួយក្នុងចំណោមគ្រាប់ព្រួយដ៏សំខាន់បំផុតនៅក្នុងបំពង់របស់អ្នកដែលមានចិត្តចង់បាញ់ឱ្យចំគោលដៅ។

<u>គោលការណ៍ទី ៥: ការទទួលខុសត្រូវ</u>

*"លុះដល់ក្រុងយេរូសាឡិមហើយ នោះពួកជំនុំ ពួកសាវ័ក និងពួកចាស់ទុំក៏រាក់ទាក់ទទួលគេ រួចគេថ្លែងប្រាប់ពីគ្រប់ការទាំងអស់ដែលព្រះបានធ្វើដោយសារខ្លួន"* (កិច្ចការ ១៥:៤)។

គោលការណ៍ទីប្រាំគឺជាការទទួលខុសត្រូវ។ រូបមន្តគ្រប់គ្រងដ៏ល្បីល្បាញមួយនិយាយថា "កុំគិតពីគោលនយោបាយជាលាយលក្ខណ៍អក្សរ និយោជិកត្រូវយកចិត្តទុកដាក់ចំពោះអ្វីប្រធានមើល"។ សិស្សរបស់យើងត្រូវមើលឃើញថា អ្នកដឹកនាំរបស់ពួកគេមើល និងទទួលស្គាល់ការបម្រើដែលលះបង់ គឺអ្នកដឹកនាំរំពឹងទុកថាការបម្រើគឺជាសញ្ញាសំគាល់ដ៏ចម្បងរបស់សមាជិក។ ឱកាសសម្រាប់ចែកចាយអំណរ សំណួរ និងការបាក់ទឹកចិត្តដោយសារការអនុវត្តន៍គួរតែមានជាទៀងទាត់ និងបម្រុងទុកនៅក្នុងការថ្វាយបង្គំរួមគ្នា នៅក្នុងក្រុមតូច និងនៅក្នុងក្រុមទំនួលខុសត្រូវ។ នេះគឺជារបៀបមួយផ្សេងទៀតដើម្បីផ្តល់ឱកាសនៅក្នុងរចនាសម្ព័ន្ធ និងភ្លាមៗសម្រាប់ឱ្យសិស្សរបស់យើងធ្វើទីបន្ទាល់អំពីអ្វីដែលព្រះជាម្ចាស់បានធ្វើ និងអ្វីដែលពួកគេកំពុងរៀន នៅពេលពួកគេបម្រើ។ ឱកាសសម្រាប់ការទទួលខុសត្រូវត្រូវតែមាននៅក្នុងការថ្វាយបង្គំរបស់យើង គឺឱ្យបានទៀងទាត់ និងញឹកញាប់។ អេសាយ ៥៨ រំលឹកយើងថា ការបង្ហាញចេញសេចក្តីស្រឡាញ់ដែលហ៊ានលះបង់របស់ព្រះជាម្ចាស់គឺជារបៀបដ៏សំខាន់មួយនៃការថ្វាយបង្គំដ៏ពិត។

គោលការណ៍ទី ៦: ការលើកទឹកចិត្ត

*"ដូច្នេះ ចូរកំសាន្ត ហើយស្អាងចិត្តគ្នាទៅវិញទៅមក ដូចជាអ្នករាល់គ្នាកំពុងតែធ្វើហើយនោះដែរ"* (១ថែស្សាឡូនីច ៥:១១) ។

*"ដូច្នេះ បើសិនជាមានសេចក្តីដាស់តឿនណាក្នុងព្រះគ្រីស្ទ ឬសេចក្តីកំសាន្តណារបស់ផងសេចក្តីស្រឡាញ់ ឬសេចក្តីប្រកបណាផងព្រះវិញ្ញាណ ឬសេចក្តីទន់ចិត្ត និងសេចក្តីអាណិតអាសូរណា នោះចូរបំពេញសេចក្តីអំណររបស់ខ្ញុំដោយអ្នករាល់គ្នាមានគំនិត មានសេចក្តីស្រឡាញ់តែ១ ទាំងរួបរួមចិត្តគ្នា ហើយគិតតែផ្លូវ១ដូចគ្នាចុះ"* (ភីលីព ២:១-២) ។

គោលការណ៍ទីប្រាំមួយគឺការលើកទឹកចិត្ត។ ការលើកទឹកចិត្តមានសារៈសំខាន់ជាពិសេសសម្រាប់សិស្សដែលគ្មានបទពិសោធន៍។ អំណរជាដរាបនៅក្នុងការបម្រើកើតឡើងដោយឯកឯង នៅពេលដែលរបៀបរស់នៅបម្រើត្រូវបានអនុវត្តទៅជាទម្លាប់។ អ្នកដើរតាមព្រះយេស៊ូវដែលកំពុងរៀនអំពីភាពជាសិស្សពិតប្រាកដត្រូវការការលើកទឹកចិត្តដែលបានមកពីការទទួលស្គាល់ ការទំនាក់ទំនងនៅក្នុងក្រុម និងការណែនាំ។ ការលើកទឹកចិត្ត និងការទទួលស្គាល់យ៉ាងដូច្នេះ មិនគួរលើកតម្កើងសិស្សទេ តែលើកតម្កើងព្រះអម្ចាស់ដែលសិស្សបម្រើវិញ។

គោលការណ៍ទី ៧: ការអបអរ

*"ចូរដំកើងព្រះយេហូវ៉ាជាមួយនឹងខ្ញុំចុះ ចូរយើងព្រមគ្នាលើកព្រះនាមទ្រង់ឡើង"* (ទំនុកដំកើង ៣៤:៣) ។

ចុងបញ្ចប់ យើងមកដល់គោលការណ៍ទីប្រាំពីរ គឺការអបអរ។ នៅពេលដែលខ្ញុំឃើញអ្វីដែលមនុស្សអបអរ ខ្ញុំដឹងយ៉ាងច្បាស់អំពីអ្វីដែលពួកគេឱ្យតម្លៃ។ អ្វីដែលយើងអបអរឆ្លុះបញ្ចាំងឱ្យឃើញពីគុណតម្លៃរបស់យើង។ ប្រសិនបើយើងឱ្យតម្លៃលើចំនួនជាងការស្តាប់បង្គាប់ យើងនឹងអបអរចំនួនមនុស្សដែលយើងបាន"ផ្សាយដំណឹងល្អឱ្យ" ចំនួនមនុស្សដែលបានទទួលពិធីបុណ្យជ្រមុជទឹក ចំនួនក្រុមជំនុំដែលបានដាំ ឬចំនួនសមាជិកថ្មីនៅក្នុងពួកជំនុំ។ យើងអាចអបអរការទាំងនេះបានមិនខុសទេ។ ប៉ុន្តែប្រសិនបើគោលដៅចុងបញ្ចប់នៃការខិតខំប្រឹងប្រែងរបស់យើងគឺថ្វាយសិរីល្អដល់ព្រះជាម្ចាស់ នៅពេលដែលសិស្សរបស់យើងបម្រើដោយនៅក្នុងព្រះនាមរបស់ព្រះអង្គ ការអបអររបស់យើងគួរតែឆ្លុះបញ្ចាំងឱ្យឃើញគុណតម្លៃនោះ។ នៅពេលដែលយើងឃើញសិស្សរបស់យើងបម្រើ ចូរអបអរ! ចូរថ្វាយសិរីល្អដល់ព្រះអម្ចាស់ដែលជួយយើងឱ្យអាចធ្វើជាសិរីល្អរបស់ព្រះអង្គបាន។

យ៉ាងដូចម្តេច? យើងអាចនិយាយរឿងបាន។ យើងអាចនិយាយអំពីការលំបាក ការភ្ញាក់ផ្អើល និងភស្តុតាងដែលយើងបានឃើញការអន្តរាគមន៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ ចំនួនរីកចម្រើនឡើងល្អ ប៉ុន្តែពួកបរិសុទ្ធដែលបម្រើគឺជាភស្តុតាងអំពីផលផ្លែអស្ចារ្យជាងចំនួនទៅទៀត។

ឧទាហរណ៍ខាងលើនេះឆ្លុះបញ្ចាំងឱ្យឃើញពីរបៀបដែលពិភពលោកកំពុងសំឡឹងមើលនេះ មើលឃើញសិរីល្អរបស់ព្រះជាម្ចាស់នៅក្នុងយើង និងតាមរយៈយើង ។

តើមានការប្រាប់ដោយប្រយោលអ្វីខ្លះសម្រាប់ពួកជំនុំដែលយើងដាំ និងអ្នកដែលយើងបង្កើតឱ្យទៅជាសិស្ស...

- ប្រសិនបើបំណងព្រះហឫទ័យពិតប្រាកដរបស់ព្រះជាម្ចាស់គឺបើកសំដែងសិរីល្អរបស់ព្រះអង្គ?
- ប្រសិនបើយើងបង្ហាញចេញសិរីល្អរបស់ព្រះអង្គ តាមរយៈការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ?
- ប្រសិនបើយើងគឺជាសិរីល្អរបស់ព្រះជាម្ចាស់ តាមរយៈការឆ្លុះបញ្ចាំងពីអត្តចរិតរបស់ព្រះអង្គ?

សូមអនុញ្ញាតឱ្យខ្ញុំផ្តល់ជូនការប្រាប់ដោយប្រយោលបីៈ

១. យើងត្រូវរំលឹកចាំមិនត្រឹមតែជំហានដំបូងៗរបស់មហាបេសកកម្មប៉ុណ្ណោះទេ ប៉ុន្តែសំខាន់បំផុតនោះ យើងមិនត្រូវភ្លេចអំពីទំនាក់ទំនងរវាងការស្តាប់បង្គាប់របស់យើងជាមួយនឹងសិរីល្អរបស់ព្រះជាម្ចាស់ "នៅផែនដី ដូចជានៅស្ថានសួគ៌ដែរ" ។

២. ទោះបីជាប្រើយុទ្ធសាស្ត្របង្កើតអ្វីក៏ដោយ យើងត្រូវឱ្យប្រាកដថា យុទ្ធសាស្ត្រនោះត្រូវបានកសាងនៅលើគោលការណ៍ដ៏សំខាន់មួយនៅក្នុងព្រះគម្ពីរសម្រាប់អភិវឌ្ឍសិស្សដែលថ្វាយសិរីល្អដល់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់ពួកគេ ។

៣. យើងត្រូវវាយតម្លៃការផ្សាយដំណឹងល្អ ការដាំពួកជំនុំ ការបង្រៀន និងការបង្កើតសិស្សរបស់យើង ដោយមិនមែនវាស់តាមរយៈចំនួនទេ ប៉ុន្តែតាមរយៈភស្តុតាងអំពីសិរីល្អរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់សិស្ស ។

ឱ ព្រះវរបិតានៃយើងខ្ញុំអើយ

សូមអត់ទោសឱ្យយើងខ្ញុំដែលមិនបានស្មោះត្រង់ចំពោះបំណងព្រះហឫទ័យរបស់ព្រះអង្គ ។ សូមកុំគ្រាន់តែជួយយើងខ្ញុំឱ្យផ្សាយដំណឹងល្អ ដាំពួកជំនុំ និងបង្រៀនបញ្ញត្តិរបស់ព្រះអង្គប៉ុណ្ណោះឡើយ ។ សូមជួយយើងខ្ញុំបង្រៀនអ្នកដែលព្រះអង្គនាំមកឱ្យទូលបង្គំមើលថែនោះ ឱ្យធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ។ ព្រះអង្គមានគោលដៅឱ្យព្រះនាមរបស់ព្រះអង្គត្រូវបានលើកតម្កើងឡើង ។ សូមជួយឱ្យយើងខ្ញុំមានគោលដៅថ្វាយសិរីល្អដល់ព្រះអង្គតែមួយប៉ុណ្ណោះ ហើយនៅក្នុងដំណើរការនេះ សូមឱ្យយើងខ្ញុំក្លាយជាសិរីល្អរបស់ព្រះអង្គកាន់តែខ្លាំងឡើងៗ ។ យើងខ្ញុំសូមដោយនៅក្នុងព្រះនាមរបស់ព្រះយេស៊ូវដែលបានបង្រៀនយើងខ្ញុំឱ្យអធិស្ឋានថា "ឱ ព្រះវរបិតានៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌អើយ សូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យព្រះហឫទ័យទ្រង់បានសម្រេច..." អាម៉ែន!

ចប់

**

ខ្ញុំស្គាល់យុវជនជនម្នាក់ជាជាតិអាហ្វ្រិក ពេលដែលខ្ញុំបានជួបគាត់នោះ គាត់មិនមានការងារធ្វើទេ។ ព្រះជាម្ចាស់បានប្រើគាត់ធ្វើជាកត្តាលិករ ដើម្បីផ្គត់ផ្គង់ឱ្យមានសាលារៀនសម្រាប់កុមាររាប់រយនាក់នៅក្នុងសហគមន៍ក្រីក្រមួយ។ តាមរយៈការបង្រៀនរបស់យើង គាត់បានដឹងថា បញ្ញត្តិនៅក្នុងបទគម្ពីរឱ្យបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មិនអាស្រ័យលើធនធាន ឬសមត្ថភាពរបស់គាត់ទេ ប៉ុន្តែអាស្រ័យលើការស្តាប់បង្គាប់នៅក្នុងពេលបច្ចុប្បន្នរបស់គាត់។ គាត់និយាយថា "ខ្ញុំបានខំធ្វើជាគ្រីស្ទបរិស័ទល្អ ខ្ញុំដឹងអំពីរបៀបប្រាប់មនុស្សអំពីព្រះយេស៊ូវ ប៉ុន្តែមានការមួយដែលខ្ញុំមិនបានដឹង គឺខ្ញុំមិនបានដឹងថា ការស្តាប់បង្គាប់ព្រះយេស៊ូវមិនមែនជាជម្រើសចង់ធ្វើក៏បាន មិនចង់ធ្វើក៏បាននោះទេ គឺជាសេចក្តីដែលត្រូវតែធ្វើ"។

ដោយបានយល់បែបនេះ គាត់បានប្រព្រឹត្តដោយជំនឿ។ គាត់ និងមិត្តភក្តិរបស់គាត់បានស្ម័គ្រចិត្តបង្រៀនកុមារនៅក្នុងមូលដ្ឋានឱ្យចេះអាន និងចេះគណិតវិទ្យា ដោយមិនបានទទួលប្រាក់ឈ្នួលរយៈពេលប្រាំបីខែ។ ព្រះជាម្ចាស់បានធ្វើការយ៉ាងអស្ចារ្យនៅក្នុងសហគមន៍ក្រីក្ររបស់យុវជននេះ និងបានចាប់ផ្តើមដំណើរការមួយដែលនាំឱ្យមានសាលាបឋមសិក្សាជាច្រើនកន្លែង សាលាអនុវិទ្យាល័យមួយកន្លែង និងបានដាំពួកជំនុំតាមមូលដ្ឋានជាច្រើនដែលមានសមាជិក គឺជាអ្នកដែលបានមើលឃើញពីការបង្ហាញចេញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះកូនរបស់ពួកគេ។ សូមកត់សម្គាល់ថា ការផ្សាយដំណឹងល្អ និងការរីកចម្រើនឡើងនៃពួកជំនុំមិនមែនជាគោលដៅទេ ប៉ុន្តែទាំងអស់នេះមានឡើង ដោយជាលទ្ធផលកើតចេញពីការបង្ហាញចេញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

មានកម្មវិធីសិក្សាល្អៗជាច្រើនសម្រាប់ការបង្កើតសិស្ស ប៉ុន្តែកម្មវិធីទាំងនេះកម្រនាំទៅរកការអនុវត្តន៍ដែលអាចមើលឃើញនឹងភ្នែកណាស់ គឺគ្រាន់តែជាច្បាប់ខាងវិញ្ញាណ ឬជាការផ្សាយដំណឹងល្អដែលគិតពីខ្លឹមសារមេរៀន។ ការណែនាំឱ្យអនុវត្តមេរៀនជាញឹកញាប់មានលក្ខណៈស្រពិចស្រពិលយ៉ាងខ្លាំង ធ្វើឱ្យមិនសូវមានការប្រព្រឹត្តិតាមទេ។ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព ការណែនាំនៅក្នុងមេរៀនត្រូវប្រាប់អំពីភាពជាក់លាក់ ការរៀបចំផែនការ និងទំនួលខុសត្រូវនៅក្នុងការបម្រើ។ ឧទាហរណ៍ ពេលដែលរៀនមេរៀនហើយ មិនមែនគ្រាន់តែណែនាំសិស្សថា "ចូរចេញទៅហើយស្រឡាញ់អ្នកជិតខាងរបស់អ្នក"ប៉ុណ្ណោះទេ អ្នកដឹកនាំក្រុមអាចសួរថា "តើអ្នកមានអ្នកជិតខាងណាម្នាក់ដែលមានសេចក្តីត្រូវការ ហើយអ្នកអាចជួយបំពេញបាន មុនការជួបជុំលើកក្រោយទៀតរបស់យើងដែរឬទេ?" "តើសេចក្តីត្រូវការនោះគឺជាអ្វី? តើអ្នកនឹងធ្វើអ្វី ដើម្បីបំពេញសេចក្តីត្រូវការនោះ? តើអ្នកនឹងធ្វើនៅពេលណា?"។ ការអនុវត្តន៍គួរតែមានលក្ខណៈច្បាស់លាស់នៅក្នុងន័យថា ការអនុវត្តន៍នោះអាចសម្រេចបានចប់សព្វគ្រប់នៅក្នុងបរិបទដែលមានការងារផ្សេងទៀត និងមុនការជួបជុំលើកក្រោយទៀត។

ប្រសើរណាស់ហើយដែលសិស្សគួរតែស្វែងរកព្រះជាម្ចាស់ និងសម្រេចចិត្តអំពីរបៀបដែលគេនឹងអនុវត្តមេរៀនមុនពេលចេញពីថ្នាក់។ ប្រាកដណាស់ ព្រះវិញ្ញាណបរិសុទ្ធប្រហែលជានាំមកនូវឱកាសបម្រើដែលមិនបានរំពឹងទុកជាមុន។ ឱកាសដែលមិនបានរំពឹងទុកជាមុននោះក្លាយទៅជាអាទិភាព។ ប៉ុន្តែការសម្រេចចិត្តជាក់លាក់ថានឹងធ្វើអ្វីមួយបង្កើតសេចក្តីតាំងចិត្ត និងការឆ្លៃប្រឌិត។ ការអនុវត្តន៍ដែលបានជ្រើសរើសទុកជាមុនគួរតែជាអ្វីមួយលើសពីកិច្ចការដែលសិស្សធ្វើជាធម្មតា ដើម្បីឱ្យសិស្សនោះរីកចម្រើនឡើង។ នៅចុងបញ្ចប់ ការអនុវត្តន៍គួរតែតម្រូវឱ្យអ្នកដែលកំពុងធ្វើកិច្ចការបម្រើមានការលះបង់ផ្ទាល់ខ្លួន។

នៅកន្លែងណាដែលអាចធ្វើបាន ការអនុវត្តន៍តាមមេរៀនដែលបានរៀនគួរតែត្រូវបានរៀបចំផែនការឱ្យទៅជាធាតុមួយនៅក្នុងគ្រប់ការសិក្សាព្រះគម្ពីរ ឬមេរៀនបង្កើតសិស្ស។ ការអនុវត្តន៍ត្រូវការពេលវេលា ប្រហែលជាមួយភាគបីនៃពេលវេលាដែលមាន។ គ្រូបង្រៀន ឬអ្នកបង្កើតសិស្សមួយចំនួនស្ទាក់ស្ទើរនឹងឱ្យពេលវេលាដ៏ច្រើននោះសម្រាប់ការអនុវត្តន៍។ ខ្ញុំសូមសួរសំណួរមួយៈ តើលោកអ្នកចង់បានមួយណា សិស្សចេះច្រើន ប៉ុន្តែមិនអនុវត្តអ្វីដែលពួកគេចេះ ឬអ្នកដើរតាមព្រះយេស៊ូវដែលចេះតិច ប៉ុន្តែអនុវត្តអ្វីដែលពួកគេចេះ?

សម្រាប់ព័ត៌មាន និងជំនួយបន្ថែមទៀតអំពីគោលការណ៍ទាំងនេះ សូមទៅកាន់គេហទំព័ររបស់ *the Disciple Nations Alliance and/or Harvest – www.disciplenations.org and www.harvestfoundation.org* ។

សំណួរសម្រាប់ពិភាក្សាតុមូល

១. តើលោកអ្នកឯកភាពដែរឬទេនឹងសេចក្តីដែលបានលើកឡើងនៅព្រឹកនេះថា ព្រះជាម្ចាស់ចង់ឱ្យពួកជំនុំធ្វើលើសជាងផ្សាយដំណឹងល្អ ដាំពួកជំនុំ និងបង្រៀន?

២. តើមហាបេសកកម្មត្រូវការឱ្យមានការបង្រៀនអំពីការស្តាប់បង្គាប់ដែរឬទេ?

៣. តើលោកអ្នកគិតថា ការស្តាប់បង្គាប់តាមការបង្រៀនមានទំនាក់ទំនងជាមួយការបំផ្លាស់បំប្រែយ៉ាងណា?

៤. តើពួកជំនុំអាចសម្រេចមហាបេសកកម្ម ដោយគ្រាន់តែធ្វើឱ្យកាន់តែច្រើនអ្វីដែលខ្លួនកំពុងធ្វើបានដែរឬទេ? ប្រសិនបើមិនអាចទេ តើត្រូវផ្លាស់ប្តូរអ្វី?

៥. តើយើងនឹងធ្វើអ្វីតាមកម្រិតរៀង១ខ្លួន និងតាមកម្រិតរួមគ្នា ដើម្បីប្រោសភាពខ្ទេចខ្ទាំរបស់អ្នកដែលនៅជុំវិញយើងឱ្យបានជា?

៦. តើយើងនឹងធ្វើអ្វីតាមកម្រិតរៀងៗខ្លួន និងតាមកម្រិតរួមគ្នា ដើម្បីបង្ហាញពីព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះភាពខ្វះខាតនៅក្នុងគ្រួសារ ពួកជំនុំ សហគមន៍ និងមជ្ឈដ្ឋានខាងសាច់ឈាមរបស់យើង?

៧. តើលោកិយដែលកំពុងតែសម្លឹងមើលមានការភ្ញាក់ផ្អើលដែរឬទេ ដោយបានឃើញភស្តុតាងអំពីការអន្តរាគមន៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង និងនៅក្នុងការបម្រើរបស់យើងដល់អ្នកដទៃ?

៨. នៅពេលសហគមន៍ដែលពួកជំនុំរបស់យើងបម្រើនៅក្នុងនោះ មើលមកពួកជំនុំរបស់យើង តើពួកគេមើលឃើញមនុស្សដែល "ឱ្យរហូតដល់ឈឺចាប់" ដើម្បីប្រោសភាពខ្វះខាតនៅក្នុងសហគមន៍របស់យើងដែរឬទេ?

៩. តើមនុស្សនៅក្នុសហគមន៍របស់យើងមើលឃើញ និងស្តាប់ឮយើងយកអាសាគ្នាទៅវិញទៅមកដែរឬទេ? តើពួកគេសង្កេតឃើញអ្វី?

១០. តើមនុស្សនៅក្នុងសហគមន៍របស់យើងបានប៉ះពាល់ចិត្តដោយសារសិរីល្អរបស់ព្រះជាម្ចាស់ តាមរយៈភាពចៅរ៉ៅ រាក់ទាក់របស់យើងដែរឬទេ?

១១. តើយើងជឿដល់កម្រិតណាថា ការបំផ្លាស់បំប្រែស្របតាមព្រះគម្ពីរអាស្រ័យលើការស្តាប់បង្គាប់?